# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និង អក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ


បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ៖ លោក ភិយ-ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកសាសនា៖ ព្រះទេពសត្ថា ស៊ូ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ



| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| លោក ភិយ-ប៊ុក ក្រមការ | សុភាសិតអង់គ្លេស .................... | ១៦១ |
| — — | ឧភិទមហគ្គៈគន្ធី .......................... | ១៦៥ |
| ព្រះឃ្លាំង ឧង | រឿងភោគកុលកុមារ (តមក) .............. | ១៧២ |
| ប-ប៊ុក ក្រមការ | អង្គរកេរ្តិ៍ដំណែលខ្មែរ ...................... | ១៨៤ |
| វិបុលកវីសេនា នូ-កន | រឿងសាមកុក (តមក) ..................... | ១៨៩ |
| ភង-សាភិត | រឿងព្រេងភូមា (តមក) ..................... | ២០៦ |
| ប្រវ៉ាភណ្ឌ ឈឹម-ណាក | រឿងក្មេងកំព្រា (តចប់)................. | ២១០ |

សាសនា

| | | |
|---|---|---|
| លោក ម៉ុញ-តាត្រី តំណាងរាស្ត្រ | ពុទ្ធសាសនានិងពាហិរសាសនា (តមក)... | ២១៦ |
| ឃុនបណ្ណានុរក្ស ប៊ូ-ប៊ូ | ខុរប្បជាតក.................................. | ២៣៤ |



ឆ្នាំទី ២២ — លេខ ៣ ខែមីនា ឆ្នាំ ១៩៥០ — ដំឡៃជាវ ១ ឆ្នាំ ១៥៨ រៀល

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Sattha So-Hay membre de la Commission du Tripitaka

## TABLE DES MATIÈRES

**Partie littéraire :**

| | | page |
|---|---|---|
| M. Ray-Buc Kramakar ( I. B. ) | Proverbes anglais (suite)........ | 161 |
| — id — | Recueil des Paroles de Gandhi..... | 165 |
| Neak oknha Brah khleang Nong | Bhogakula kumara (suite)......... | 172 |
| M. Ray-Buc Kramakar (I. B ) | Angkor, patrimoine national des Khmes | 184 |
| Néak oknha Vibularajaséna Nou Kân | Histoire de Sam-kok (suite)........ | 189 |
| M Sang-Savat Ministère des Finnances | Contes birmans (suite) ............ | 206 |
| Chhim-Nak (I. B.) | L'enfant orphelin (Conte) (suite et fin | 210 |

**Partie religieuse:**

| | | |
|---|---|---|
| M. Ménh-Nakry Député | Le Bouddhisme et les autres religions (suite).. ....... | 216 |
| Bou - Po (I. B.) | Khurappajataka.............. | 234 |

22e Année: No 3 Mars 1950 — Prix d'abonnement: 145$00 par an.

# សុភាសិត អង់គ្លេស

## លោកក៏យ - ប៊ុក ក្រមការ ដកស្រង់រៀបរៀង

( តមក )

១៦ – បើលោកប្រាថ្នាចង់បានទ្រព្យទាំងឡាយ លោកត្រូវត្រាច់តាមឲ្យជាប់ពីក្រោយវា ( ត្រូវស្វែងរក ) ។

" ស្វែងរកទើបបាន ព្យាយាមប្រឹងប្រែណា ទើបសម្រេចផល
វីរិយាជាគ្រូ មាសប្រាក់គំគរ ទ្រព្យធនកុំខ្វល់ ស្វែងរកពៀសជាប " ។

១៧ – បើសិនណាជាលោកមិនអាចលក់មហាជាតិ សូម្បីតែមួយ ក៏លោកត្រូវធ្វើស្មៀនខានមិនបាន ។

" បើរកមហាជាតិមិនបាន មិនត្រូវខានធ្វើការរបស់ខ្លួន
កើតមកជាមនុស្សប្រឹងមាំមួន ធ្វើស្រែដាំសួនកុំនៅស្ងៀម " ។

១៨ – ចូរជឿកប្បាសខ្លួនឯង ទើបព្រះជាម្ចាស់បញ្ជូនអំណោយមកឲ្យ ។

" កុំរង់ចាំព្រេងកស្មាបុណ្យ ត្រូវតែរកទុនកុំខ្លាចនឿយ
ខ្លួនត្រូវធ្វើការងាររឿយៗ ខំធ្វើឲ្យហើយកុំទុកស្អែក " ។

១៩ – បើមានប្រាថ្នាចង់ឡើងឲ្យដល់កំពូល ត្រូវឡើងពីកាំជាន់ទាបជាមុន ។

" ចង់ឡើងគេហដ្ឋានលើឡើងជណ្ដើរ
កាត.បះស៊ើរបង់ធ្វើធំមិនសម្រេច
មិនទាន់រៀនធម៌វិន័យបង់ពុទ្ធកិច្ច
ចង់តែត្រាប់ខ្លួនវារកទើបបេះការ " ។

២០ — ការងារគ្រប់យ៉ាងក្នុងលោកសន្និវាសនេះ មិនមែនសុទ្ធតែប្រើកម្លាំងកាយទេ ។

**វិល្យមការលីតុន**

" ការងារលោកប្រើកម្លាំងកាយពា
ចិត្តប្រាជ្ញាព្យាយាមកិច្ចទើបគប់ផល
ចិត្តប្រែងខានបានសំរេចព្យាយាមដល់
ទ្រព្យធំគល់យសធំកើតតាមប្រាជ្ញា ។

២១ — នៅក្រោមព្រះអាទិត្យនេះ មានមនុស្សជាច្រើននាក់ ដែលធ្វើជាការប្រយោជន៍ ចំពោះមនុស្សមួយនាក់ " ។

**ប៊ីរុងក្នុងរឿង "The Corsaire"**

" មនុស្សច្រើនកោដិ ជាងមន្ត្រីប្រាប ពាណិជលំអាន ធ្វើការប្រយោជន៍ មនុស្សម្នាក់តាមស្ពាន ព្យាយាមប្រឹងប្រាណ បបរថ្ងៃគ្មានឈប់ ... "

២២ — ចូរក្រុមខ្លួនរសជាតិនៃឋាសនចិត្តដែលជាផលរបស់ការងារៗ

**ឡុងហ្វេល្លូវក្នុងរឿង "Masque of Pandora"**

"ការងារសុចរិត ធ្វើហើយប្រព្រឹត្ត ហាសនចិត្តផ្សាយ រសជាតិឧត្តម ប្រសើរពណ្ណកាយ ព្រឹព្រួចអង្គកាយ សប្បាយចំឡែក" ។

២៣ – អ្នកណាព្យាយាមធ្វើការឲ្យបានយ៉ាងស្អាតបរិសុទ្ធបំផុត ដែលជនសាមញ្ញមិនងាយនឹងធ្វើបាន អ្នកនោះឈ្មោះថាធ្វើការប្រសើរ ។

"បណ្ឌិតធ្វើការ ឈូសចាំងបន្ទារ ល្អស្អាតឥតហ្មង ធ្វើកិច្ចសារពើ ព្យាយាមជាច្បង កោសកៃច្រើនដង ទើបបានសោភ័ណ" ។

២៤ – វេលាជាមាសជាប្រាក់ ។

**ប៊ុលវែរលីត្តុង**

"វេលាជាមាសប្រាក់ទ្រព្យថ្លៃ បេះប្រើសំចៃយបថ្លៃបាន វេលាខូចខាតវិនាសប្រាណ វេលាអាក់ខានជួបទុក្ខៈទោស" ។

២៥ – វេលានាំមកនូវសេចក្ដីឈ្លាសវៃ ។

"បេះប្រើពេលអាចពុះពារទបសត្តបាន
ពូជកល្យាណជាតិបណ្ឌិតកំណាញ់កាល
វេលាឲ្យប្រាជ្ញាឈ្លាសវៃក្លៃព្រាល
វេលាផាលនាំបណ្ដុះពូជឧស្សាហ៍" ។

២៦ – វេលាជាជីវិតរបស់ជួនវិញ្ញាណ ។

**ឡុងហ្វេល្យូ**

“ វេលាជីវិតសមភាព ប្រាជ្ញប្រាប់វេលាថ្នមគួរគាប់
ជីវិតសត្វលោកពេលព្រឹក ថ្ងៃយប់ទៀតពេលកសាងជាតិ ” ។

២៧ — គ្រប់ខណៈមានមនុស្សស្លាប់ ហើយគ្រប់ខណៈមានមនុស្សកើត ។

**តែណានីសុន ក្នុងរឿង · Vision of sin”**

“ កើតស្លាប់គ្នា យល់ភាពមរណា ស្គាល់កើតជីវិតកល សខ្មៅក្នុងលោក ឃើញមគ្គយល់ផល ភ្លឺងងឹតជល់ កុំច្រលំធម៌ពីរ ” ។

២៨ — អ្នកទទួលបំរើគេតាមកំណត់វេលា អាចមានអាយុ៣០ឆ្នាំ តែរូបរាងកាយចាស់គ្រាំគ្រា ស្លាប់ទៅក៏សឹងមាន ឬអាចមានអាយុ ៨០ ឆ្នាំ តែរូបរាងកាយពេញកំឡាំងដូចកំឡោះ ស្លាប់ទៅក៏សឹងមាន ។

“ ពួកទាសកម្មករបំរើគេ គ្មានពេលទំនេរមួយនាទី
ឈ្មោះថាហាក់កាយពលរ័ធ អាយុកសីរស់យឺនយូរ ” ។

២៩ — នៅក្រោមព្រះអាទិត្យ គ្មានកិច្ចអ្វីដែលគួរឲ្យតូចចិត្តជាង ការបណ្តែតបណ្តោយឲ្យខូចពេលអស់មួយថ្ងៃ ដោយខ្លួនមិនបានធ្វើការអ្វីសោះឡើយនោះទេ ។

“ ខូចវេលាខាតទ្រព្យមាសប្រាក់ ខូចបុណ្យយសស័ក្តិវិនាសខ្លួន
ខូចវេលាខាតវិជ្ជាក្បួន ដូចត្រគួនដុះក្នុងខែប្រាំង ” ។

**( មាគត )**

# ជុំភាសិតមហាត្មគន្ធី

Recueil des paroles de Gandhi

*លោក ក៉យ-ប៊ុក ក្រមការ ដកស្រង់រៀបរៀង*

---

## ក). ស្រង់ពីសារព័ត៌មាន ហ្យូនអាំង "Jeune Inde"

១ — ខ្ញុំបានបង្ហាញដោយដាក់ស្តែងនូវគ្រោងការណ៍ដែលប្រកបដោយសេចក្តីអង់អាចរបស់ខ្ញុំ, ខ្ញុំស្អប់ខ្ពើមការស្លាត់កំបាំង ដូចជាខ្ញុំស្អប់បទឧក្រិដ្ឋ, ខ្ញុំសូមថ្លែងសេចក្តីអរគុណចំពោះព្រះជាម្ចាស់ ដែលខ្ញុំបានដឹងជាយូរយារមកហើយថា ការស្លាត់កំបាំងជាអំពើអកុសលមួយចំពោះបញ្ហានយោបាយ, វិទ្យាដែលខ្ញុំរក្សាទុកក្នុងចិត្តមិនត្រូវលាក់លៀមទេ ។

សារព័ត៌មាន ថ្ងៃ ០២ ខែធ្នូ ១៩២០
(អំពើអកុសលនៃការស្លាត់កំបាំង)

២ — ត្រូវប្រើកាលវេលាវែងឆ្ងាយទូលាយណាស់ មុននឹងធ្វើរឿងក៏វរកាន់ប្រទេសឲ្យទទួលស្គាល់នូវច្បាប់ព្រហ្មវិហារផង . . . ដល់ទៅថ្ងៃណាមួយគេរកឃើញ ហើយប្រើបាននូវថាមភាពថ្មីមួយ ចំណែកអ្នកដែលបានរកឃើញនូវថាមភាពពីជាន់មុន គេគាប់ពោលថា អ្នកនោះជាឧត្តម-បុគ្គល (Idéaliste) ឬជាអចិន្តបុគ្គល (utopique), លោកវិស្វករអគ្គិសនីត្រូវគេចោទថាជាអ្នកមានចរិតខុសពីជនធម្មតា (maniaque) ឬជាមនុស្ស

•មួតក: (fou) ចំពោះមជ្ឈមណ្ឌលយានគមនាគមន៍ដែលប្រើ•ស្ទ័ន (locomotion à vapeur) លុះត្រាតែកិច្ចការនេះបានសម្រេចផលប្រយោជន៍ជាស្ថាពរដោយសារបង្កើតខ្សែភ្លើងអគ្គិសនី ទើបគេឈប់ពោល, ត្រូវរកពេលវែងឆ្ងាយ ដើម្បីនឹងដេញខ្សែព្រហ្មវិហារឲ្យជាប់ទាក់ទងរវាងប្រទេសមួយជាឯកច្ឆន្ទ, តែតាមសេចក្តីយល់ឃើញនូវព្រឹត្តិការណ៍នៃទីបញ្ចប់ នឹងអាស៊ីបូព៌ាក្នុងពេលមុនៗនេះ ចំពោះរឿងដែលមានសារៈសំខាន់ យើងបានឃើញថា សកលលោកក្នុងសម័យបច្ចុប្បន្ន បានពិនិត្យយល់ជាក់ច្បាស់ថា ពលភាព (force) តែមួយយ៉ាង មិនអាចនឹងដោះស្រាយនូវបញ្ហាផ្សេងៗនេះបានចំពោះប្រជាជាតិនិងបុគ្គល ហើយជារបៀបប្រែនយោបាយសេដ្ឋកិច្ច ដោយមិនព្រមចូលសមាគមនឹងជាតិដែលកាន់កាប់ប្រទេសអាណានិគម មានសភាពវិសេសជាងប្រើកងទ័ពជើងគោក-ទឹក ។

សារពត៌មាន ថ្ងៃ ២៣ខែមិថុនា ១៩១៩

៣ — ប្រតិបត្តិតាមច្បាប់របស់រដ្ឋ នេះជាតំលៃនៃពលរដ្ឋដែលត្រូវធ្វើដោយសេរីភាពសព្វខ្លួន, ធ្វើតាមបង្គាប់នៃរដ្ឋដែលប្រព្រឹត្តអយុត្តិធម៌ពេញលក្ខណៈ គឺប្រព្រឹត្តជំទាស់នឹងសីលធម៌ ព្រមទាំងសេរីភាព ។

បញ្ហាមានសារៈសំខាន់ជាបំផុត

សារពត៌មាន ថ្ងៃ ១០ ខែវិច្ឆិកា ១៩២០

៤ — ខ្ញុំស្វែងរកសេចក្តីពិតជាប្រណិត គឺធ្វើឲ្យសម្រេចខ្លួនក្នុងខ្លួនឯង ហើយឲ្យសម្រេចនូវជោគវាសនារបស់ខ្លួន គឺប្រាថ្នាឲ្យបានដល់សុក្រឹតភាព (perfection), ខ្ញុំបានដឹងដោយលំបាកថា ខ្លួនខ្ញុំល្ងង់ខ្លៅច្រើន ហើយការដឹងបែបនេះជាពលភាពរបស់ខ្ញុំ ដោយហេតុថា កម្រនឹងមានមនុស្សដឹងខ្លួនឯងថាអាត្មានៅខ្វះខាតបំណេះវិជ្ជាគ្រប់យ៉ាង ។

សារពត៌មាន ថ្ងៃ ១៤ ខែធ្នូ ១៩២១

៥ — អហឹសាវិតក្ក "ការត្រិះរិះមិនបៀតបៀនអ្នកដទៃ" ដោយសភាពជាថាមវន្ត ដែលមនោធម៌អាចតស៊ូនឹងធន់: នៃមហាពលពាល (tyran), បុគ្គលណាប្រព្រឹត្តតាមច្បាប់វិសេសនេះ អាចតស៊ូនឹងពលភាពនៃប្រទេសដែលមានគំនិតទុច្ចរិត តាំងបណ្តាលឲ្យប្រទេសនោះធ្លាក់ចុះអន់ថយ ឬអាចធ្វើឲ្យប្រទេសនោះប្រែប្រួលបាន ។

សារពត៌មាន ថ្ងៃ ១១ ខែកញ្ញា ១៩២០

៦ — ឱព្រះជាអម្ចាស់អើយ !

សូមព្រះអង្គណែនាំប្រទេសតណ្ហាឲ្យចូលទៅកាន់មាគ៌ាជីវសុទ្ធ !

សូមព្រះអង្គបង្ហាត់បង្ហាញឲ្យប្រទេសនេះកាន់លទ្ធិ "ស្វទេសី[1]" !

---

១ ស្វទេសី មកពី ស្វទេស ប្រែថា "ប្រទេសរបស់ខ្លួន ស្រុករបស់ខ្លួន" (វចនានុក្រមខ្មែរ ភាគ ២) ។

សូមព្រះអង្គប្រមូលជាតិឥណ្ឌូ, មហាហ្ម័ត, ប៉ារស៊ិស(១), គ្រិស្ត, ស៊ីខ ដែលរស់នៅក្នុងប្រទេសឥណ្ឌាឲ្យមានសាមគ្គីជាឯកច្ឆន្ទ !

៥ វិច្ឆិកា ១៩៤៧

៧– បញ្ហានយោបាយ បានដល់ការតស៊ូដើម្បីប្រយោជន៍រាស្ត្រ គឺតស៊ូនឹងសេចក្តីភ័ន្តច្រឡំដែលកើតមកពីច្បាប់អយុត្តិធម៌ ។

៥ វិច្ឆិកា ១៩៤៧

៨– បើប្រជារាស្ត្រលែងខ្លាចនូវពលភាព។ រដ្ឋាភិបាលក៏ត្រូវដឹងខ្លួនដោយខ្លួនឯងថា កំលាំងជាសភាពប្រើការមិនកើត ចំពោះបុគ្គលដែលមិនខ្លាចនូវកំលាំង គឺអ្នកនោះលែងហ៊ានប្រើកំលាំងនេះតទៅទៀតហើយ, បុគ្គលណាដែលមានសិទ្ធិទៅកាន់តំណែងរដ្ឋការ ច្រើនពេញចិត្តក្នុងការប្រើទារុណកម្មចំពោះប្រជារាស្ត្រ ក្បួននៃការត្រួតត្រាគឺត្រូវមាន

---

១ ប៉ារស៊ិស ជាឈ្មោះពួកអ្នកកាន់លទ្ធិស្សូរអាស្ត្រ (Zoroastre) នៃប្រទេសពែរ្ស ដែលបានភៀសមកនៅក្នុងប្រទេសឥណ្ឌាជាច្រើន, ស្សូរអាស្ត្រ ជាអ្នកកែទម្រង់សាសនា (Réformateur) នៅប្រទេសអ៊ីរ៉ង់ កើតនៅក្នុងឆ្នាំ ៦៦០ មុនគ្រិស្តសករាជ ហើយមរណភាពក្នុងឆ្នាំ ៥៨៣ មុនគ្រិស្តសករាជ, លទ្ធិនេះមានសារៈសំខាន់ពីរយ៉ាងគឺ ១ ព្រះជាម្ចាស់ល្អ គេហៅថា អាហ៊ុយរ៉ា ម៉ាកដា (Ahura Mazda) និងព្រះជាម្ចាស់អាក្រក់ គេហៅថា អង្គ្រាមញូ (Angra Mainyou) ហើយព្រះទាំងពីរនេះធ្វើសង្គ្រាមនឹងគ្នាទៅវិញទៅមក ។

(វចនានុក្រមបារាំង)

កំលាំងគ្រប់គ្រាន់បរិបូណ៌សម្រាប់អាត្មា ល្មមនឹងបង្ខិតបង្ខំប្រជារាស្ត្រ ដោយប្រើវិធីបំភ័យទាល់តែប្រជារាស្ត្រព្រមចុះចាញ់, ហើយរដ្ឋាភិបាល ដែលគេទុកជាវត្ថុសម្រាប់បង្គាប់នូវផ្លូវការបាន លុះត្រាតែរដ្ឋាភិបាលនោះ តាំងដោយឆន្ទៈនឹងសេចក្ដីព្រមព្រៀងរបស់ប្រជារាស្ត្រ, រដ្ឋាភិបាលដែល ធ្វើឲ្យប្រជារាស្ត្រប្រតិបត្តិតាមច្បាប់ ដោយប្រើចុងគ្រឹបជាអាវុធ ។

ថ្ងៃ ២២ ខែតុលា ១៩១៩

៩ — ខ្ញុំជឿថា ពួកពលរដ្ឋមានសិទ្ធិដកហូតសាមគ្គីភាពពីពួកការ បើសាមគ្គីភាពនោះនាំឲ្យថោកទាបឬខូចកិត្តិយសដល់ខ្លួន, នេះជាឧបាយ មួយដែលបង្ហាញឲ្យពួកការដឹងជាក់នូវសេចក្ដីទោមនស្សរបស់ប្រជា-រាស្ត្រ ។

សន្ទរកថាលោកមហាត្មគន្ធី

ថ្លែងនៅទីក្រុងគិតិល្លា ពីថ្ងៃ ៣ ខែធ្នូ ១៩១៩

១០ — ពិតមែនតែការចលនាមិនសុទ្ធតែនាំទៅកាន់វឌ្ឍនធម៌, ឯការចលាចលក៏មិនសុទ្ធតែនាំទៅកាន់ជោគជ័យដែរ ។

ថ្លែងការណ៍ចំពោះព្រ.មហាក្សត្រ

ពីថ្ងៃ ៣១ ខែធ្នូ ១៩១៩

១១ – ការបលាបលគ្មានវិន័យ គឺជាកិច្ចការធ្វើដោយកំហឹងទល់កំហល់ដោយកាចនឹងដោយកម្មិកភាព នាំឲ្យយឺតយូរនូវវឌ្ឍនធម៌របស់ប្រជាជាតិ ហើយនាំឲ្យបានទោសទុក្ខដែលមិនគួរមានទោះ ដូចជាឃាតកម្មនៃលោកសាល្ហ័យន៍វល្លាបាគហ៍ ( Jallianwalla Bagh ) ជាដើម ។

ថ្លែងការណ៍ចំពោះព្រះមហាក្សត្រ
ពីថ្ងៃ ៣១ ខែធ្នូ ១៩១៩

១២ – សេចក្ដីទុកចិត្តជាគុណធម៌មួយ, ទុព្វលភាពនាំមិនឲ្យទុកចិត្ត ។

ថ្លែងការណ៍ចំពោះព្រះមហាក្សត្រ
ពីថ្ងៃ ៣១ ខែធ្នូ ១៩១៩

១៣ – សមូហភាព គឺមានបំណងជាមួយគ្នា មានសេចក្ដីសង្ឃឹមជាមួយគ្នា និង ធ្វើទុក្ខលំបាកជាមួយគ្នា ។

សម្ពន្ធភាពជាតិឥណ្ឌា - មហាហ្ម័ត
ថ្ងៃ ២៩ ខែកុម្ភៈ ១៩២០

១៤– បុញ្ញកម្មធ្វើក្នុងពេលដែលមានជោគជ័យតែងមានដាំខ្សែជាងគេ ។

... គ្មានប្រជាជាតិណាអាចឡើងទៅកាន់ស្ថានឧត្តមបានទេ បើគ្មានពលិកម្ម ( Sacrifice) ហើយគេអាចពោលពីពលិកម្មចំពោះតែសេចក្ដីសុចរិត មិនមែនសេចក្ដីទុច្ចរិតឡើយ ។

ប្រកាសទៅទីក្រុងអារ៉ាត្សារ
ពីថ្ងៃ ៣ ខែមិនា ១៩២០

១៥ – សភាពត្រួតត្រាលើខ្លួនឯងបាន ជាច្បាប់សម្រាប់ខ្លួនយើង, សុក្រិតភាពដ៏វិសេសនិងឋិតថេរនៅបាន មកពីសភាព ត្រួតត្រាខ្លួនឯងដោយម៉ឺងម៉ាត់, សេចក្តីទុកត្រឡប់ជាបដិមា (គោលសម្គាល់) ( Symbôle ) នៃជាតិមនុស្ស ។

អហិំសកៈព

៨ វិច្ឆិកា ១៩២០

១៦ – ការបង្ហាញឲ្យឃើញជាក់ស្តែងដោយកិច្ចធ្វើពលិកម្មនេះឯង ជាហេតុធ្វើឲ្យប្រទេសជាតិរុងរឿងទៅអនាគត, ប្រទេសជាតិមិនមែនរុងរឿងដោយផ្គងចិត្តបង្ខំធ្វើអាឃាតព្យាបាទនោះទេ ។

សន្និបាតថ្ងៃ ៦ និង ១៣ ខែមេសា ១៩២១

ថ្ងៃ ០១ ខែមីនា ១៩២០

១៧ – មែនពិត បើតាមមតិរបស់មនុស្ស, មានភាគច្រើនយល់ថា ការប្រើអក្សរជាតិនេះ អាចនឹងញ៉ាំងមនុស្សឲ្យគិតការឧត្តមបាន ។

បុព្វហេតុនៃអក្សរជាតិ

២១ ខែមេសា ១៩២០

( មានត )

## រឿងភោគកុលកុមារ

# អ្នកឧកញ៉ាព្រះឃ្លាំង ឯង រៀបរៀង

(តមក)

---

មាតាបិតា ស្ដាប់បុត្រទូលលា ទឹងវិលវ័ងខ្វី ព្រមព្រះហឫទ័យ ក្សត្រិយ៍ទាំងពីរ បើកបុត្រគ្នាប្រិយ តាមព្រះចិន្ដា ៗ ព្រះបាទសត្តកុជ រាជាវិសុទ្ធ វិសេសត្រាស់ថា ហៃកូនសំឡាញ់ ចង់ចេញឃ្លាតឃ្លា ទៅនគរ ពារាណសី ៗ អាពុកតាមបិត្ត ពិតពុំខាំងឃាត់ កូនស្ងួនប្រិមប្រិយ ចូរបាផ្ចិតផ្ចង់ កម្មង់ស្មារតី គ្រប់គ្រងធានី ជានារាស្ត្រផង ៗ តាមដោយទសពិធ រាជធម៌សុចរិត កុំឲ្យមានហ្មង រដ្ឋរាស្ត្រសព្វហាន គតមានភ័យផង តាមដោយគន្លង ធម៌ព្រះទូន្មាន ៗ មួយគឺធម៌ថា ឲ្យសង់សាលា ជីកស្រះសង់ស្ពាន ឧស្សាហ៍ខ្វល់ខ្វាយ ចែកចាយធនធាន ធ្វើបុណ្យឲ្យមាន សព្វថ្ងៃប្រក្រតី ៗ គំរប់ពីរចាំ រក្សាសីលប្រាំ លុះថ្ងៃអដ្ឋមី ថ្ងៃឧបោសថ ស្រគត់ឥន្ទ្រិយ សូមសីលប្រាំបី កាន់កុំខានខាន ៗ ជាគំរប់បី ចូរបាប្រណី ដាក់ព្រះរាជទាន ចិញ្ចឹមយាចា សេនាទាហាន បរិវារគ្រប់ប្រាណ ថែទាំរក្សា ៗ ជាគំរប់ ៤ ចូរចិញ្ចឹមខ្លួន តាមដោយសម្មា សមាណបរិភោគ អគ្យាគអធ្យា កុំគិតបំពា បំពានទ្រព្យគេ ៗ ជាគំរប់ ៥ ចូរចងចិត្តចាំ កុំកាន់វៀចវេ គិតដោះទុក្ខរាស្ត្រ ទាំងផ្ដាសឲ្យថែ ឲ្យជួនប្រើប្រែ ព្រះទ័យឲ្យទន់ ៗ ជាគំរប់ ៦ មាន តបៈឲ្យបាន ឈ្នះចិត្តលោភលន់

លះលែងទោសា មោហាទូទាំង បានបរិបូណ៌បុណ្យ បំបាត់បាបបង់ ។ ជា៧សោត កុំឲ្យក្រេវក្រោធ ធុរធាប់ឲ្យវង់ ឲ្យរិះរំពឹង ជញ្ជឹងគិតគន់ ហ្ឫទ័យឲ្យត្រង់ ឲ្យត្រូវធម្មា ។ គំរប់ ៨ កុំបៀតជីវ៍ ជីវិតហឹង្សា មនុស្សសត្វឥតទោស សន្តោសមេត្តា អាសូរករុណា ជួយជន្មជីវី ។ ជា ៩ បទ ឲ្យមានអំណត់ អំណរខន្តី សច្ចំបរមត្ថ កាន់កតវេទី គិតគុណជននី ជនកប្រធាន ។ គំរប់១០ដោយ ធម៌ថាប្រើឲ្យ មហាក្សត្រក្សេមក្សាន្ត ត្រែកទ្រង់សណ្ដាប់ តាមច្បាប់បុរាណ កុំឲ្យបំពាន បំពារក្រៅក្រិត្យ ។ បើក្សត្រឯណា គិតកាន់សីលា តាមដោយទសពិធ រាជធម៌ទូន្មាន ទើងបានសម្រឹទ្ធិ សម្រេចដូចចិត្ត ដូចក្ដីប្រាថ្នា ។ កង្វះលាភកិយ៍គាប់ កើតកើ្ដរគំនាប់ គំនិតថ្លៃថ្លា បរលោកនឹងបាន ឋិតឋានសួគ៌ា ដល់តុសិតា សោយសម្បត្តិបុណ្យ ។

ទើបព្រះជននី ទូន្មានបុត្រី ថាកូនសួនតន ចូរបេះចាំចិត្ត គំនិតឲ្យធូន ឲ្យគិតឲ្យគន់ ឲ្យគួរដោយធម៌ ។ ចូរនាងចងចាំ រក្សាសីលប្រាំ សព្វថ្ងៃរៀងរាល់ ថ្ងៃបេត្រអដ្ឋមី បុណ៌មីឲ្យស្គាល់ ឲ្យដឹងកិច្ចការ កាន់សីលប្រាំបី ។ ព្រះពុទ្ធប្រទាន ទេសនាទូន្មាន អស់អគ្គស្រីលស្រី ប្រាំពីរប្រការ សព្វសារពើពី ក្រិត្យក្រមនារី ចូរនាងស្ដែងស្ដាប់ ។ មួយឈ្មោះពេជ្ឈឃាដ ភរិយាប្រមាទ ស្វាមីក្រៅច្បាប់ ចិត្ត៤ប្រការ ឥតសាវឥតសព្ទ ឥតសីលពុំគាប់ ពុំគិតកើ្ដរកោះ ។ ចិត្ត១រង្វរស

ប្រទះប្រទូស្ត ប្រកាន់ឈ្លោសឈ្លោះ សំឡុកសំឡឹង មុខរឹងបោកបោះ
ពោលពាក្យទ្រគោះ ឲ្យប្តីអៀនអាក់ ។ ចិត្ត១ស្រើបស្រាល ស្រើប
ស្រាលវៃស្នេហ៍ស្នាល ស៊ុំស្ងួនរមរ៉ក្ស នឹងប្រុសដទៃ អាល័យស្មោះស្ម័គ្រ
បើប្រុសឲ្យរាក់ សិល្បសាស្ត្រធ្វើប្ដី ។ ចិត្តមួយមិនគោត មិន
មានកំណោត គម្ពង់ស្វាមី រំលើកគិះរៀល ជំនៀលរៀលស្តី មើល
ងាយស្រដី ពោលពាក្យពុំក្រែង ។ ចិត្តមួយកំណាច គំនិតគិតខ្លាច
ចរចេញចាយបែង និយាយស្រដី ធ្វើមប្តីតម្លែង ទោសស្វាម៉ីឯង
ឲ្យអស់គេស្តាប់ ។ រីចោរភរិយា មានចិត្តប្រាំប្រា–ការកត់ត្រង់ត្រាប់
មួយមិនចង់ធ្វើ សារពើការគាប់ ពុំចង់ប្រដាប់ ប្រដាឲ្យប្តី ។ មួយ
ចិត្តចង់ចាយ ទ្រព្យប្តីពុំស្តាយ គិតតែទិញទី លួចលាក់ប្តាំងបិទ
ឲ្យមិត្តភ្ញាប្រិយ បង្ហិនទ្រព្យប្តី ពុំប្រះផ្គត់ផ្គង់ ។ មួយបើប្តីបាន
មាសប្រាក់ធនធាន រក្សាពុំគង់ ពុំគិតដាក់ទុក ទំនុកបម្រុង
អម្រស់ឲ្យបង់ ឲ្យបាត់ពុំស្តាយ ។ មួយចេះតែស្អាង បញ្ចោរបរាង
ពព្រើមពព្រាយ ពព្រើតដើរលេង ដាល្បែងសប្បាយ ចង់មានសហាយ
ស្អប់ប្តីអាត្មា ។ មួយបើស្វាមី ស្រឡាញ់មេត្រី ស្ម័គ្រស្មោះចិន្តា
រឹងធ្វើចិត្តធំ ពតំពុំពានា នាំពាក្យចរចា ឲ្យអាក់ចិត្តប្តី ។ សត្រូវភរិយា
មានប្រាំមួយប្រា–ការកាចអប្រិយ មួយចិត្តពុំចង់ បំរុងស្វាមី ពុំតាម
ចិត្តប្តី យកតែចិត្តឯង ។ មួយខ្ជិលការការ ខ្ជិលរៀបអាហារ អណ្តាប់
តាក់តែង បើបានចំណី សោតទីតែឯង ពុំគិតពុំក្រែង ពុំទុកឲ្យប្តី ។

មួយប្តីចង្រៃ ចង់ជាធំក្រៃ លើសល្វែងស្វាមី ពោលពាក្យថ្នាំងថ្នាក់ ឲ្យអាក់ចិត្តប្តី មិនមានមេត្រី ចងចិត្តស្នេហា ។ មួយចិត្តកំណាច ប្រ-ចណ្ឌកោងកាច ប្រចាំប្រុស្សា បញ្ចៀសផ្គងប្តី(១) ឥតបីមេត្តា ប្រទេចផ្តាសា ពុំគិតបាបកម្ម ។ មួយប្តីមានទុក្ខ មានទោសពុំសុខ សឹងមើលបំណាំ បើប្តីឈឺថ្កាត់ ដេរប្រាតពុំចាំ ពុំចង់រក្សាថ្នាំ រកពេទ្យមើលប្តី ។ មួយប្តីប្រដៅ សារពើកក់ក្តៅ ក្រិតក្រមច្បាប់ស្រី ចិត្តពោរទទឹង ទៅទឹងស្វាមី ពុំយកពាក្យប្តី ចងជាទោសា ។ ភរិយាទាំង៣ នេះកាឡ-កណ្ណី ចិត្តពោរប្រុស្សា ជាស្រីទុរល័ក្ខណ៍ អបល័ក្ខណ៍មោហា អស់អត្ថទោសា បៀនបាមុខ ។ លុះលែងជាតិពី កំណើតលោកិយ ធ្លាក់ទៅនរក ទូកទូរទ ពេកពានពុំសុខ រងទោសរងទុក្ខ ទៅនាអវិចី ។ លង់លុះមួយកល្ប ទៀងទើបរួចរាល់ មកកើតជាស្រី ផ្កាមាសអប្ប-ល័ក្ខណ៍ ជាយក្ខិនី កំព្រាគតប្តី ចំរាយជាតិជាក់ ។ បើស្រីនោះបាន ធ្វើបុណ្យឲ្យទាន សឹងតែបួសធ្លាក់ ទៅទំនរក ទលទុក្ខឥតអាក់ ឥតឯមានអ្នក ណាទឹងប្រោសប្រាណ ។ ទោះព្រះបញ្ញា ធិកសាងសទ្ធា វិរិយាញាណ ត្រេចត្រាស់ទទ្រង់ ស្រោចស្រង់ពុំបាន ហេតុស្រីនោះមាន ចិត្តបៀសក្រៅធម៌ ។ កូនអើយចូរចាំ ចូរចេះចៀសកម្ម ចៀសការអម្បាល នេះទឹងបានសុខ ទៅមុខវៀងកល់ វៀងរួចទៅផល់

---

១. ច្បាប់ខុះហា មិនវេះផ្គាប់ប្តី ។

ស្គិទិញានពិត ៗ ហៃបុត្រីពន្លក ចូរនាងរៀនយក ក្រឹត្យក្រមសុចរិត ភរិយាទាំង ៤ ស្រីសួនបងចិត្ត ចាំចេះគន់គិត តាមដោយធម៌ថា ៗ ប្រាប់មួយហៅមាតុ – ភរិយាជាអាទិ៍ មានចិត្តប្រុំប្រា ការកល់មួយមាន ចិត្តក្បាន្តរក្សា ទុកដាក់ទ្រព្យា ពុំឲ្យបង់បាត់ ៗ មួយចិត្តឈឺផ្សាល ស្វាមី គាប់កាល មានះទោសទំណូទាត់ កាលកើតរោគា ដកឈឺថ្កាត់ ថែទាំ ប្រយ័ត្ន ប្រយោជន៍រក្សា ៗ មួយចេះបំរើ រណ្តាប់សារពើ ពស្តុ គោជនា បើបានអាហារ ត្រកាលឲ្យជា ពុំឃ្លានគោក្តា ទុកឲ្យស្វាមី ៗ មួយរករបស់ អម្រែអម្រស់ អម្រែងឲ្យប្តី គាត់តែងជួញប្រែ ធ្វើស្រែក ធី ធ្វើការប្រក្រតី បំពុមអាត្មា ៗ មួយចេះសង្វាត រាប់អានសាច់ញាតិ រៀមច្បងមេបា បើបានពស្តុការ អាហារពិសា ចែកជូនគ្រប់គ្នា មិន មានកំណាញ់ ៗ នានាមកតិទ៍ – ភរិយាលក្ខណ៍ស្រី ៤ប្រការមិញ មួយចេះចាំចិត្ត គន់គិតស្រឡាញ់ ស្វាមីអស់អញ ជួបបងអាត្មា ៗ មួយមានអំណត់ អំណរអាចអត់ ចិត្តចាំស្នេហា មែនមានមេត្រី ឥតបី ក្រោធា ទាសីទាសា ពុំបង់ទោសទុក្ខ ៗ មួយមានសីលវត្ត បំរើ ប្រណិប័តន៍ ស្វាមីជាសុខ មិនមានខឹងខាន់ ប្រច័ណ្ឌញ៉ិកញ៉ក់ អាចឲ្យ ស្រណុក ចិត្តប្តីសព្វថ្ងៃ ៗ មួយមានមារយាទ ការកើតអត្ថអាត្មា មាន ខ្មាសប្រពៃ បើយល់បុរស ប៉ុណ្ណប្រុសដទៃ មិនមានមូលមៃ-ត្រី គ្រេកគ្រេសប្រោល ៗ នានាមាមិត្ត-ភរិយាសុចរិត មាន ៧ ប្រការ

មួយមិនប្រទុស្ត រំងែរូសបណ្ដាល រកហេតុរង្គាល ឲ្យអាក់ចិត្តប្ដី ។ មួយមានគំនិត គំនាប់ស្នេហ៍ស្និទ្ធ ស្នេហ៍ស្មាលមេត្រី ស្រឡាញ់ស្មោះស្ម័គ្រ ពក់ពាក់នឹងប្ដី ដូចយល់មិត្រពី ចំងាយមកដល់ ។ មួយមានអនុកូល ផ្ដេកផ្ដិតមិត្រមូល ជាសុខសាន្តសល់ នៃបទិត្យស្វាមី ឥតបីមានគល មានកើតអំពល់ អំពីអ្វីៗ ។ រីទោសភរិយា មានលក្ខណ៍បីប្រការ - ការគួរជាស្រី មួយមានពាក្យស្មោះ ពិរោះស្រដី ផ្ញើខ្លួនលើប្ដី ឲ្យប្ដីអាណិត ។ មួយបើស្វាមី ស្រឡាញ់អស់ស្រី បរិពារក្រមក្រិត្យ ចេះជួយស្រឡាញ់ បំពេញតាមចិត្ត តាមដោយគំនិត ស្វាមីស្ម័គ្រស្មោះ ។ មួយបើស្វាមី ខេចឹងស្រដី រំលើកបោកបោះ ជេរពោលប៉ុន្មាន ពុំហានឆ្លើយឈ្មោះ សារសងទ្រគោះ តតបពាចា ។ ច្បាប់ស្រីទាំងបួន បំពួកបួរសួន រៀនរំរះរក្សា ក្នុងលោកិយតាប់ គំនាប់ថ្ងៃថ្ងា ឥតគេនិន្ទា ដៀលដល់មកម្ដាយ ។ អស់អគ្គទេព្រក្ស មហេសីសក្តិ៍ ទេវតាទាំងឡាយ ប្រោមប្រែងឲ្យពរ បវរពណ្ណកាយ សួស្ដីសុខសប្បាយ យសសក្ដាក្ដាត់ ។ លុះលែងជាតិបាន សោយសុខពិមាន ពិតពត្តុសិត សក្តិសម្រិទ្ធិ សិរីវិង វិវេងឋានបិតប្រាង្គប្រាសាទសួគ៌ ។ សុទ្ធសឹងកែវកើត សម្រាប់ត្រចេត ត្រៃឈស្រាំងស្រល ស្រីទេពកញ្ញា រៀបគ្នាជាជួរ គង់គាល់គាប់គួរ ក្រាស់ក្រៃក្រៀបក្រា ។ លុះអស់កំណត់ សួគ៌សោតច្យុត មកកើតនៅនា

ត្រកូលក្សត្រក្សាន្ត មែនមានប្រាជ្ញា ល្អដូចទេវតា ជាស្រីគ្រប់លក្ខណ៍ ។ នឹងបានជាមហា - មហេសីក្សត្រា បរមចមចក្រ — ពត្រាធិរាជ អំណាច ឯកអគ្គ ឯកឯងនីវអ្នក — ណានឹងផ្ទឹមបាន ។ ទោះបីប្រាជ្ញា នឹកនឹងបង់ជា កន្សៀព្រុទ្ធញាណ សឹងបានដូចចិត្ត គនគិតរិះធ្យាន ហេតុស្រីនោះមាន មារយាទគួរគាប់ ។ សួនសង្ក្រសាប កុំភ្លាំងភ្លាត់ភ្លេច ប្ចូរបេះចាំចាប់ ស្ពរកេរៀនរិះ ត្រេកត្រេះត្រងត្រាប់ ធម៌នេះជាច្បាប់ ប្រសើរឯកស្រី ។

ពីរព្រះរាជបុត្រ ពិសេសលំទុត អង្គទូនសិរសី ទទួលបណ្តាំ ចងចាំពាក្យពី ព្រះវរជននី ជនកទូនាន ។ សេចក្រែបក្រានគ្រប់ អរទុន អង្គអ — ភិវាទក្សត្រក្សាន្ត លុតលាៈបញ្ញទៅ ដល់ក្រៅវាំងបាន ឡើងគង់រាជយាន មាសមៃយល់យង់ ។ មន្ត្រីសេនា សេនីយោធា រៀបរៀងរាយរង់ គួរត្រន្ទីរត្រ ផ្ទុំហែព្រះអង្គ យាត្រាត្រេចត្រង់ ដល់ច្នេរជលសា ។ ចុះចាកយានយាង ព្រះបាទនាំនាង ឡើងលើកេត្រា អស់មុខមន្ត្រី សេនីសេនា ប្រដាប់ប្រដា ប្រុងប្រៀបស្រេចស្រាប់ ។

**ចទភូជង្គលីលា**

រាជាបេស្តាគួរគាប់ បន្ទូលប្រាមប្រាប់ អស់អង្គយោធា ។ គោះគងស្គរផងមហិមា ស្រេចស្រាវយុត្កា ហើយហូតស្មាបក្តោង ។ ព្រះពាយធ្យព្វផ្សាយយោលយោង រលកសំពោង សំពៅលឿនលង ។ កេត្រាសេនាមុខម - ន្ត្រីត្រៀបៈពកពន់ បើកហែក្សត្រថ្ងៃ ។ ដល់ទៅជម្រៅ

ជលស័យ សុខសប្បាយក្រៃ មិនមានភ័យភិត ។ ស្តេចថ្កើងរុងរឿងរង្វើ
នាងនាដនៃបទិត្យ គង់គន់មន្ត្រា ។ ត្រីស្ពង់យង់ប្រែកាឡា ផ្គាមផ្គាំងកជ
ក–ហ៊ឹហក់ហៃបហៃល ។ ល្ហុះល្ហិបគល់ព្រៃចបៃល កុក្ករកុក្កល មង្ករ
ពិន្ទុង ។ ត្រីខ្ជាបង្កាបង្កង កន្ទ្រប់កន្ទ្រង មិងព្រលក្រុសក្រាញ់ ។ យ៉ុក
ក្សកក្រញ៉ូកកញ្ចាញ់–ព្រាស់ប្រលឹងលេញ កញ្ចាក់ស្វាស្វាត ។ ប្រកែង
អណ្តែងអណ្តាត - ផ្ទែផ្ទោកក្ទាំងហាត ក្ទាំងហាយគុព្រា ។ ប្ញាដូថ្ងាម្ញុប៉ាម៉ា
កែសកែប្រាក់ប្រា កន្ទរកន្ទាយ ។ ផ្សាតច្បរក្រពាតសណ្តាយ ផ្តោ
សំពោបាយ អណ្តើកត្រសៃ ។ ផុះផែលអង្កែលអង្កែ ហៃបហៃល
ព្រៀវព្រៃ ររកភោត្តា ។ ក្សត្រៃច្បៃពេទត្តលា ស្តេចទតមន្ត្រា
ក្រសាលសុខសាន្ត ។ កេត្រាសេនាទាហាន បើកប៉ាក្សត្រក្បាន្ត
លឿនលន់ផ្ទុកផ្ទោះ ។ ទៅដល់មណ្ឌលទៀបកោះ ស្តេចឲ្យបៀតបោះ
យុគ្គានិត្យទៅ ។ ចុះក្ខានសំប៉ានមាសខ្មៅ លំលាឡើងទៅ ប្រពាតលើ
ខ្សាច់ ។ ស្រីង្គារបរិពារហែស្តេច យាងយាត្រាត្រេច ដោយច្នេរជល-
សា ។ ខ្សាច់សល្អះល្អសោភា មានមទង្គសិលា អណ្តាតសមុទ្រ ។
មានកំពោះហាសសុទ្ធ ព្រាលខ្ទៅប្រាកដ ដុះឡើងប្រាងប្រួង ។ ខ្ទៅគ្រឹងដី
រុក្ខាមគ្រោង ក្តាមសេះខ្យងហោង ខ្យងហៀនខ្យងសង្ខ ។ ងាវគ្រែង
ចាក់ប្រែងប្រឡាំង - កាសកៀរញីទាំង គូគៀងរកដី ។ ព្រះមហា-
ក្សត្រាធិបតី នាំព្រះប្អូនស្រី មុខមន្ត្រីបរ ។ ដាសដេរដោយច្នេរសាគរ

ស្រើបស្រួលអឹងអរ ក្រេមក្សាន្តចិន្តា ។ លុះដារដំណើរដលសា ស្តេច យានយាត្រា ប្រពាតលើកោះ ។ ព្រឹក្សាសាខារបោះ របេបចន្ទោះ ដុះដោយពណ៌រ៉ា ។ កែវកោដ្ឋដុះជោតក្រិស្នា ក្ងាំពូក្ងាំពា ក្ងាំពាក់ដំប៉ូ ។ ម្ហោរបញ្ចកាណ៍ ទូវទួនពីសី ចំនួនសចំនួនប្រាល ។ ខ្ទិងខ្ទាស់ប្រមុះសោម សារ-គុណអគ្គេរឃ្មាល ត្បាលដែកល្ងួតលាស ។ ត្រៀកត្រសំចិត្ត-បុស្ស៍សហស្ស គុណគុយរាជភាស លំពូស្ទេចស្ទែរ ។ សន្តារទន្សាទន្សៃ អគ្គត់អង្ក្រៃ ដែកដឹះដងដឹង ។ បឹសប្រយគោមួយឆ្នង់ថ្នឹង ព្រុសព្រះទ្រ-ហ៊ឹង ព្រះកំបាត់ដើមតារ ។ ទូរេនមនមៀនមន្ទារ — បុស្ស៍បឹងកុមារ-តេជ្រៃតសន្ទ្រាក ។ ស្លូលស្វាយទំលាយរាក់រោគ រាំងរៃម័កជោក ម័ក-ប្រែងម័កប្រាង ។ ឈើជាសំពាក់កាងកាង លៀតល៉ៅតលាំងលាំង-សាគសាបត្តួបពាន ។ ឆាំឆាស្អែងស្វាបត្រគេន ស្លាស្លាបល៉ាទាន ល្អង់ល្អត់សជា ។ ក្រសាំងខ្ទុះណាំងប៉ាយស្រាំ ស្វាតស្វាយរំពា ស្វាយ៉ា ក្បាលដំរ ។ ផ្ទុកផ្ការផលាំទុំខ្ចី សេនាមន្ត្រី បេះបានបូតបូតយ៉ ។ ព្រះ អង្គពីរពាក្រពណ៌រ៉ាយ សោយផលសប្បាយ ស្រេចស្តេចលីលា ។ រឹងប្តានពិមានក្បែ្រតា ស្រេចស្រាវយុត្តា ហើយហូតក្តោងទៅ ។ ត្រេច ត្រង់ជម្រង់ជម្រៅ រាងជ្រោយសំដៅ កណ្តាលផលសាន ។ ខ្យល់ យានត្រូវក្តោងប៉ែកបាន ដល់ក្រុងពារា-ណាសីនគរ ។ ពលធងអឹងកង គ្រែកអរ សោមនស្សសាទរ ដាក់ក្តោងមម្នា ។ ស្រេចស្រុះបានបោះយុត្តា

ស្រេចហើយប្រាក់ គោះគងទូងស្គរ ៗ ព្រះមហាក្សត្រាក្ខូជរ នាំនាងចេញចរ ចុះចាកកេត្រា ៗ គង់យានមាសមានសេនា សេនីយោធា បើកបាំងក្លស់ក្លុម ៗ ត្រៃស័ង្ខពីងពាំងប្រគំ ហៃក្សត្រឧត្តម ឡើងគង់ប្រាសាទ ៗ មន្ត្រីសេដ្ឋីអមាត្យ ខុនណាងបត់បាទ បុស្ស្យបង្គំគាល់ ៗ ស្រឹង្គារបរិវារប្រាសប្រាល់ បំរើរៀងរាល់ សព្វទិនទិវា ៗ

## បទកាកគតិ

ស្តេចសោយពង្យស្កល់ គ្រងបរិវារពល រាស្ត្រពជរដ្ឋា ឥតភ័យ ឥតទុក្ខ សុស័ក្តិសុខសាន្តសា — ប្បាយបទមហា — ក្សត្រក្សាន្តទ្រង់ធម៌ ៗ សាងសង់ប្រដាប់ សាលាធងាប់ ល្អល្អះពីព័ណ៌ ដាក់ព្រះរាជទាន ជនជានសព្វសារ — តើពុំទើសទាល់ ព្រួយព្រះចិន្តា ៗ ស្តេចរៀបអាហារ ចំណីភ័ស្តុភារ បាយទឹកម្ហូបស្ងោ ក្រេះប្អូងច័ន្ទន៍ សុគន្ធមាលា មាសប្រាក់រតនា ករកងចិញ្ចៀន ៗ កន្ទេលបៀមបំ ខ្នល់ខ្នើយព្រែព្រំ សំពត់អាវខៀន មុងមានពានស្តក ទៀនគោក ធ្លិលសៀន ចានបន្ទះទៀន ដាក់ទានសព្វថ្ងៃ ៗ ស្តេចទ្រង់សទ្ធា ឲ្យទានទ្រព្យា អនេកច្រើនក្រៃ រណ្តាប់ចាយចេញ គិតកាញ់ដំឡៃ មាសទីមួយថ្ងៃ បីសែនតម្លឹង ៗ អស់មនុស្សក្រសត់ កំសោយទុគ៌ត ត្រេកអរអើងអឹង ខ្នើយខ្នែគមគាក់ ខ្វិនខ្វាក់ខំប្រឹង ដើរមកទ្រហឹង ទទួលរាជទាន ៗ ក្រង្ហូរក្រងយ ក្រៃផងកំព្រយ កំព្រាក្សត់មាន

ពីស្រុកស្រែក្រៅ លំនៅទូរបាន ចូលមកយកទាន សព្វទិនទិវា ៗ
រាស្ត្រប្រជាជន សឹងសុខដោយបុណ្យ បារមីព្រះមហា – ក្សត្រទ្រង់
ទសពិធ សុចរិតធម្មា អ្នកខ្សត់ប្រែជា មានមិនហោចហិន ៗ
ក្សត្រថ្ងៃវល័ក្ខណ៍ វរលោកចមចក្រ ចម:ចាភូមិ - ន្ទរធិកជា សទ្ធាវីរិ-
យិ – ន្ទ្រិយទ្រង់បញ្ញិន្ទ្រិយ បញ្ញាពលំ ៗ តែកទ្រង់សីលប្រាំ
អស្តង្គសីលចាំ ពុំភ្លាត់ភ្លេចភាំង ទូន្មានមន្ត្រី ប្រុសស្រីរាស្ត្រទាំង
នគរឲ្យតាំង រក្សាសីលធម៌ ៗ ស្តេចទូន្មានថា ហៃអស់គ្រប់គ្នា គួរ
គិតគួរស្គាល់ គិតកាន់សីលប្រាំ បង់ចាំវៀងពល់ ចៀសបាតកម្មការ
បំបាត់បាបបង់ ៗ បាណាតិបាត អ្នកណានេសាទ ចិត្តចោរហេតុបង់
ពិឃាដម្រឹគា មច្ឆាទូរអង្គ មនុស្សសត្វឲ្យបង់ ឲ្យបាត់ជន្មា ៗ អ្នក
នោះនឹងទៅ រងបាបក្តាត់ក្តៅ លំបាកនៅនា សញ្ជីពនរក ទល់ទុក្ខ
ឈឺផ្សា ទូរទន់ទូរា រូបរងយូរក្រៃ ៗ យមបាលបោះទៅ ក្នុងភ្លើង
នោះជ្រៅ ធុរឆេះក្សីណក្ស័យ ហើយរស់រូបវិញ ពុំដឹងគិតក័យ រាវិល
មកៗ ដល់មាត់រណ្តៅ ៗ យមបាលមក ចោមចាក់នឹងស្នូ មូល
ប្លុកដែកក្តៅ ចាក់នឹងលំពែង សិកសែងចោលទៅ ក្នុងទីរណ្តៅ
ភ្លើងភ្លឺពុំក្បែន ៗ កំណត់ជន្មា នរកនោះហា – យឆ្នាំប្រមាណ គន់
គិតនាឆ្នាំ ត្រូវប្រាំបួនលាន មនុស្សនេះទើបបាន មួយថ្ងៃនរក ៗ
លង់លុះរដោះ ពីនរកនោះ មកមិនដែលសុខ កើតជាមច្ឆា

មានទាផ្ទែកស្រែក គេកាប់សាប់លក់ ប្រាំរយជាតិជាក់ ៗ ទៀងទើប-កើតជា មនុស្សមានទោសា គេបាញ់គេចាក់ គេដោតគេកាប់សម្លាប់តគតក ប្រាំរយជាតិជាក់ ពិតពុំសុខអង្គ ៗ ទើបយកជាតិជា មនុស្សមានពោគា ដំបៅពកយន្ត ជាមនុស្សគមគាក់ ក្អែកខ្វាក់ខ្វិនខ្វន់ ដៃជើងក្ងែងកង់ ករគ្គតអប្រិយ ៗ ៈបំបាំនសក្តិបុណ្យ ផ្សេតផលពីមុន បានសាងមកក្តី ពៀរកម្មអាត្មា ឲ្យអាយុខ្លី ពុំឃើនជីវជីវិតដល់ចាស់ ៗ ទោះធក់ផ្ទេសផ្ទើ កាយកម្មបាបបើ បោះបង់ក្រឡាស់ក្រឡាប់លៃងលះ ប្រែប្រាសរហ័ស ដឹងដោយធម៌ច្បាស់ គន់គិតយល់យល់ ៗ ខ្លាចបាបខ្លាសបាប បៀសបាកដកប ជីវិតសត្វសល់ ពិតពុំពាធា ត្រៀងកល់ ចិត្តចាំសីលធម៌ បាណាតិបាត ៗ បានទៅកើតនាសួគ៌ាសុមហា – ពដិកាជាតិ ជាអង្គទេវបុត្រ បរិសុទ្ធស្អាងស្អាត ឋិតលើប្រាសាទ ប្រាំពីរះយោជន៍គត់ ៗ ស្រីទេពកញ្ញា ប្រាំរយអង្គាបម្រើបាំនបទ បុស្សបង្គំគាល់ រៀងកល់ប្រាកដ ប្រែកប្រកំណត់កំណាន់សព្វថ្ងៃ ៗ ប្រាំរយឆ្នាំគត់ ទិព្វទើបច្យុត មកកើតនៅឮត្រកូលក្សត្រត្រក្យូនុសន្តានថ្លៃថ្លៃ ពង់រូបល្អក្រៃ មានលក្ខណាគ្គាត់ ៗ មានកំឡាំងលន់ មានចិត្តនោះទន់ ប្រណីទុក្ខសត្វ មានគួនមានហៅ ញាតិផៅពុំព្រាត់ ពុំប្រាសខ្វាតក្ខាត់ ជាសុខដល់ចាស់ ៗ

(មានត)

អង្គរកេរ្តិ៍ដំណែលខ្មែរ

# លោក វ៉ាយ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង ដាព ក្បាញ

---

កាលខ្ញុំឃើញប្រាសាទអង្គរ ក្នុងចិត្តសញ្ជូរទៅតាមស្នែ
ព្រឺព្រួចកោតស្ញែងដល់ជាងឆ្លាក់ វិសុកម្មជាក់ខ្មែរបុរាណ ។
នឹកដល់សម័យព្រះក្សត្រា យសោវរ្ម័នជាស្ដេចចំណាន
ស៊ីវិល្ល័យថ្កុំថ្កើងស្អាងវិមាន ក្នុងចិត្តសាន្តស្ងានទេព្វនិករ ។
សម័យភព្វព្រះកេតុមាលា ខ្មែរកម្ពុជាមហានគរ
ប្រទេសធំទូលាយទន់ទ្រាយល្អ ល្បីល្បាញបវរក្នុងទ្វីបា ។
មហាអំណាចអំណោយផល ភពភូមិសកលខ្លាចបេស្ដា
អាណាចក្រប៉ាងប៉ែងអស្ចារ្យ នឹកឡើងហាសនាចិត្តរីករាយ ។
មាតុភូមិរុងរឿងពលរដ្ឋថ្លៃ មនុស្សល្អប្រពៃចិត្តសប្បាយ
គ្រឹះស្ថានមានរបៀបដ៏ស្រស់ស្រាយ មើផ្ទុះចៅហ្វាយមានកិត្តិសព្ទ ។
ឃើញនិម្មិតជនត្រេចត្រសង សួរឆ្លើយពាក្យឆ្លងគ្នាប្រាវ្ធ
មនុស្សណែនណាន់តាំងថ្ងៃយប់ យល់គ្រប់តាមភាពបែបអង្គកាយ ។
ឃើញមានផ្សារហាងលក់ទំនិញ ឃើញទិញអីវ៉ាន់ទៅស្រុកឆ្ងាយ
ឃើញអានុភាពស្រុកក្រៅផ្សាយ ឧត្តមពណ្ណរាយក្នុងលោកា ។

ឃើញមហាក្សត្របុទ្ធិជោគជ័យ ឃើញព្រះមហេសីល្បីនាមា
បុត្រាបុត្រីស្នំស្រីស្នា មន្ត្រីរាជការចតុស្តម្ភ ។
មានទ័ពដើរទឹកគោកពាសពេញ ពួកព្រាហ្មណ៍ចូលចេញសាសនាព្រហ្ម
ឥស្សរនារាយណ៍មូលជួបជុំ អង្គក្រុះកុំបុណ្យរកបកិច្ច ។
អង្គរធំជាកំពង់មហារាជ មានសិទ្ធិអំណាចលើជនស្រេច
ព្រះអង្គប្រសើរចមកពងាច់ ប្រទេសចរត្រេចជាធ្ងើមឯក ។
មានច្បារឧទ្យានបោក្ខរណី ព្រះរាជបុត្រីក្រសាលត្រេក
វិមានអាកាសល្អល្អះប្លែក ចូលសេកសេពសមក្មេងតន្ត្រី ។
ក្មេងមហោរីរបាំច្រៀង រូបដើរមានពងល្អពិសី
មានល្ខោនកំច្រៀងចរចាស្តី ភាពស្អាតប្រិមប្រិយស្រួលសប្បាយ ។
សម្បត្តិសំបើមសំបូណ៌បុណ្យ គ្រងរាជ្យព្រះគុណខ្ពស់ឆើតឆាយ
មិនមានទុក្ខភ័យបៀតព្រះកាយ សេនាប្រាជ្ញប្រាយគាល់ហ្វូងគាប់ ។
គួរឲ្យស្ញប់ស្ញែងខ្មែរបុរាណ សាងប្រាសាទបានគួរចិត្តចាប់
ក្បាច់ក្បូរជាងគួរចេះចំណាប់ បំណាង់ចុចជាប់ក្តងទយា ។
គួរឲ្យសង្វេគស្ញុតស្ញុងចិត្ត គោតក្រែងគំនិតនឹងប្រាជ្ញា
ខ្មែរសាងប្រាសាទក្តងរដ្ឋា ទុកនាមឆាយាឲ្យកូនចៅ ។
គួរយកមតិខ្មែរបុរាណ មហាអំណាចប្រាំស្ពានត្រប់ប្រជៅ
ថៃខ្មែរបច្ចុប្បន្នឲ្យយល់ជ្រៅ ចំពោះជាតិនៅជាប់នឹងនួន ។

មតិខ្មែរប្រែតាមសម័យ បណ្ឌិតប្រាជ្ញវៃតាមកាលជួន
កុំក្ដីរកស្រអាប់បុណ្យប្រាប់ខ្លួន ឬប្រាជ្ញស្លូនរីកដោយខែ ។
ត្រូវយកអង្គរអារម្មណ៍ជាតិ ព្រះពុទ្ធនាំឲសាសនាខ្មែរ
មហាអំណាចប្រាជ្ញត្រូវក ប្រឹងប្រាណខំបែររកចម្រើន ។
ប្រុសស្រីកុំភ្លេចត្រ័យសរណា ទេសជាតិសារស្នាត្រូវបង្កើន
ការនាញឹកញយចាំក្រើន ការនាឲ្យចម្រើនទើបផុតលិច ។
បើគារាជាតិធ្លាក់ដល់ដី បញ្ចេញផ្កាយថ្មីខំចរត្រេច
បើគេហដ្ឋានរលំស្រេច ត្រូវប្រកបកិច្ចរើធ្វើស្អាត ។
កុំនិទ្រាចាំព្រេងវាស្នា រុក្ខាមិនដាំម្ដេចផ្លែខាត
មិនខំស្វែងដកចង់ស្អាងជាតិ មិនប្រឹងសង្វាតរៀនចង់បេះ ។
សាមគ្គីភាពហានស្អាងជាតិ ស្រោចទឹកនាំឲឈើបានបេះ
ផ្ទៃទាសភាពជួរចិត្តឆេះ យល់មេឃស្រឡះជាតិស្វាងសម ។
គួរឲ្យស្រណោះអតីតា អង្គរខេមរាស្ងាត់ជ្រងំ
បើឃើញចិត្តតែងទូរគម ព្រោះឈើរលុំរឹតរួតរឹង ។
គតគ្រាប្រណីក្សាចររចនា ចារឹកសិលាដោយកំហឹង
គំនិរុកគួនពាលពំទុតឹង កំព្រាគ្មានពឹងអរញ្ញាក ។
បាត់ព្រះមហាក្សត្រពុទ្ធិអង់អាច វិស្វកម្មប្រាជ្ញបណ្ឌិតា
សូន្យមហេសីខត្តិយា មន្ត្រីស្រឹង្ការលាយបាត់ ។

កងពលយោធារលាយអស់ ចាកលោកសូន្យសោះជាតិវិបត្តិ
ពីរបុគ្គលសប្បុរសខ្វាត់ កម្បក់ផ្សាយផ្ទាត់ចាកសីមា ៗ
បាត់ស៊ីវិឡៃខ្មែរបុរាណ នៅតែទិព្វស្ថានថ្មសិលា
ជាគ្រឿមតិកបច្ចុប្បន្នា ស្នាដៃអស្ចារ្យដីតាយើង ៗ
ម្តេចឡើយមកនៅតែតំណែល សុរិយាដដែលខ្មែរចុះឡើង
ស៊ីវិឡៃបាត់កើតថ្មីច្រើន ឆេះលេតក្រើងសង្ខារសត្វ ៗ
បុណ្យទ្រព្យស៊ីវិឡៃនាលោកា ប្រែប្រួលធម្មតាតែងភ្ញាំងភ្ញាក់
ដូចច្រនៀលខ្នើតរនោចបាត់ ភាណវង្សអស្តង្គតរះលិច ៗ
កង់លោកវិលចុះឡើងវិញ បុណ្យបាបភាពរង់តាមកិច្ច
និស្ស័យគោកធ្លុកប៉ះដីជាប់ ចុះក្រែបទន់ទាបអាប់រាសី ៗ
បើប្រទេសថយគ្មានគេជា គ្មានបុទ្ធិពលាអន់ស្មើ
កូនចៅកុំដេកចាំសួស្តី ទឹកភពដីព្យាយាមកុំភ្លេច ៗ
បើយើងខំប្រឹងទាំងអស់គ្នា ដោយក្តីហានក្លាខំចរក្រែប
ធ្វើហើយធ្វើទៀតគង់សម្រេច សោភ័ណផលកិច្ចតាមគួរការ ៗ
ខំជួសជុលគ្រឹះស្ថានខ្មែរជាតិ សង្វាតឧហាតទាន់វេលា
ឈើក្រញូងបេងទ្រូសម្ភារ សង់ដែនភាពជាតិទឹកដី ៗ
កូនចៅខាងក្រោយខំរៀនសូត្រ កុំលោតលង់លិចផុតសេរី
ច្បាប់ធម្មជាតិសន្សឹមតិច ៗ ក្តី តក់ ៗ បាស់ថ្មីពេញបំពង់ ៗ

ធ្វើការតាមកាលឲ្យយល់គល  កុំធ្វើហួសផលហេតុភ័យល្ងង់
សម័យស្អាងជាតិតាមច្បាប់គង់  គបកែតម្រង់តម្រាគាព ។
គួរស្ងៀមប្តូពោលឈប់បង្អង់  គួរបង់ប្តូខានមិនខូចលាភ
គួរហៅនប្តូខ្វាចយល់ប្រែសាប  ដូចឃ្លោងឃ្លាកាព្យសោភតីពេះ ។
បើនឹងកាំប្រៀងត្រូវក្មេងស័ព្ទ  បើត្រួតតាមច្បាប់មាត្រាស្មោះ
ស្ងៀកពាក់ឲ្យសមសួនស័ក្តិយស  បើនឹងសាបព្រោះឲ្យជ្រើសពូជ ។

ចប់តែប៉ុណ្ណេះ

---

សុភាសិត

ដំបូលផ្ទះឆ្ងាយជាងដំបូលផ្សារ,
គូបភរិយាជិតជាងផ្ទរម្តាយឪពុក ។
សូវស្តាយបាន ប្រសើរជាងស្តាយបង់.
សូវខូចអង្គ ប្រសើរជាងអាប់កេរ្តិ៍ឈ្មោះ ។

ឃ. អ៊ិ.

# រឿងសាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

### វគ្គទី ៨

**តាំងអំពីគួនអ៊ូចេញទៅតយុទ្ធកាត់យកក្បាលហួយុងបាន រហូតដល់កង់ស៊ុនចាន ជិត លើកទ័ពទៅវាយយកស្រុកគីជីវ**

ពេលនោះចៅហ្វាយខេត្រទាំងអស់ដែលនៅក្នុងបន្ទាយ លុះបានឮស្គរសំឡេងគងស្គរដេសន្ធឹកអឺងអាប់ ក៏ប្រញាប់ប្រមូលគ្នាចេញទៅមើលគួនអ៊ូតប្រយុទ្ធនឹងហួយុង កាលបើបានចេញទៅដល់មាត់ទ្វារបន្ទាយ ស្រាប់តែឃើញគួនអ៊ូយួរក្បាលហួយុង ត្រឡប់មកបោះទុកនៅមាត់ទ្វារនោះ, នាយទ័ពនាយកងទាំងពួងត្រេកអរសប្បាយរីករាយទាំងអស់គ្នា ហើយម៉ឺមានាំគួនអ៊ូចូលទៅគំនាប់អ្នកសៀវ ។ ចូចូបានលើកពែងស្រាចេញមកគំនាប់គួនអ៊ូ ៗ ទទួលហើយគំនាប់គប ទើបលើកពែងស្រាឡើងទទួលទាន ស្រានោះក៏នៅក្តៅៗ ។

ឯតៀវហ៊ុយក៏ចូលទៅគំនាប់នាយទ័ពនាយកងហើយជំរាបថា គួនអ៊ូបងខ្ញុំបាទបានចេញទៅយកអាសា កាត់ក្បាលហួយុងមកជូនហើយ, ខ្ញុំបាទសូមយកអាសាវាយទំលាយកងទ័ពចូលទៅក្នុងស្រុកក្រុង កាត់យកក្បាលតាំងតុៈមកជូនអស់លោកទៀត ។ អួនស៊ុតឮដូច្នោះខឹងណាស់ស្រែកគំហកហើយថា បណ្តានាយទ័ពនាយកងទាំងពួង គេមិនទាន់យល់

ឃើញប្រការម្តេច ស្រេចអ៊ំលើខ្លួនមកគួននិយាយកាត់មុខអ្នកធំថាសុំអាសាទៀត ខ្លួនជាមនុស្សអាក្រក់ណាស់, ថាហើយក៏ឲ្យបណ្តេញតៀវហ៊ុយចេញអំពីទីជនុំ ។

ប៊ូច្ចូឆ្លើយថា ជម្មតាទំនៀមធ្វើសឹកសង្គ្រាម, បើអ្នកឯណាធ្វើសេចក្តីគាប់ប្រសើរក្នុងការសង្គ្រាម លោកតែងឲ្យតម្លើងតាមគុណបំណាច់យ៉ាងសមគួរ, បើអ្នកឯណាធ្វើការខុស លោកឲ្យចុះទោសយ៉ាងសាហ័ស, ដែលទីងមកខឹងត្មះតិះដៀលដោយកាន់តស្សរ៉េយសបំពោះទីប្រជុំនោះមិនសមគួរទេ ។ អ្នកស៊ុតតបថា បើកប់គានទាហានទ្បេរជាឯកជួបចេះ, ឃើងក៏នឹងមិនចូលចិត្តគិតធ្វើការជាមួយគ្នាតទៅទៀតឡើយ នឹងលើកទាហានវិលទៅស្រុកវិញ ។ ប៊ូច្ចូតបថា គ្រាន់តែនិយាយរំលឹកគ្នាជាសេចក្តីបន្តិចបន្តួចប៉ុណ្ណោះ ហៃរជាចង់លះបង់ការធំហោលនោះមិនគួរសោះ, ថាតែប៉ុណ្ណោះក៏ឲ្យកង់ស៊ុនជានាំ ឡេវពី, គួនអ៊ូ, តៀវហ៊ុយ ត្រឡប់ទៅកាន់ទីលំនៅរៀងខ្លួន ឯប៊ូច្ចូឯងក៏ឲ្យនាំយកមានទាជ្រូកលបទៅឲ្យឡេវពី, គួនអ៊ូ, តៀវហ៊ុយ ។

បណ្តាទាហានហួយុងដែលសេសសល់ពីស្លាប់នោះ ក៏នាំគ្នាត្រឡប់ចូលទៅក្នុងបន្ទាយគ័ស៊ុយក្នុនវិញ ហើយឲ្យបំរើនាំសំបុត្របកចូលទៅជំ-រាបសួរលីស៊ុក ។ បកសំបុត្រចូលទៅដល់តាំងតុះ ។ ដឹងសេចក្តីក៏ភ័យបារម្ភណាស់ ទើបប្រឹក្សានឹងលីយូ, លីយ៉ុ ថា ឥឡូវនេះហួយុងស្លាប់ហើយតើយើងនឹងគិតធ្វើដូចម្តេច? ។ លីយូឆ្លើយថា ហួយុងជាទាហានឯក

ស្លាប់អសារដូច្នេះ លើសពីទាហានទៀតស្លាប់មួយម៉ឺនក៏មិនជួន, ឯកុងគងទ័ពដែលលើកមកធ្វើការគ្រានេះ ខ្ញុំបាទដឹងថា អ្នកសៀវជាមេទ័ពធំ ឥឡូវនេះអ្នកង៉ុយជាមាអ្នកសៀវជានាហ្មឺននៅក្រុងនេះ គង់គប់គិតជឹងគំនិតគ្នាទៅវិញទៅមកជាកលសឹកពុំខាន សូមឲ្យលោកគិតសានចាប់អ្នកង៉ុយសម្លាប់ចេញចុះ ។ តាំងគុះឮដូច្នោះក៏ត្រូវចិត្ត ទើបបង្គាប់លីឈុយ, គុយគី ឲ្យនាំទាហានប្រាំម៉ឺន ទៅចាប់អ្នកង៉ុយនឹងបក្ខពួកស្រីប្រុសទាំងអស់សម្លាប់ចេញ ហើយឲ្យកាត់យកក្បាលអ្នកង៉ុយទៅដោតផ្ចាលនៅមុខបន្ទាយ គីស៊ុយគួន ដើម្បីឲ្យអ្នកសៀវជាក្មួយក្រឡេកឃើញ ហើយឲ្យលីឈុយ នាំពលប្រាំម៉ឺនតាំងទប់ឲ្យខ្ជាប់ខ្ជួនកុំឲ្យបន្ទាយគីស៊ុយគួនអន្តរាយបាន ។ លីឈុយ, គុយគីក៏នាំទាហានទាំងប្រាំម៉ឺនទៅធ្វើតាមតាំងគុះបង្គាប់គ្រប់ប្រការ ។

ឯតាំងគុះនឹងលីយូ, លីប៉ោ, ហួនតៀវ, តៀវឆេ ក៏ឃុំនាំទាហាន ១៥ ម៉ឺនលើកទៅរក្សាគយហៅលោកួន ជាប់ព្រំនឹងស្រុកក្រុងឡូកអៀង ផ្លូវចម្ងាយប្រមាណ ៥០០ សិន (២០០ គីឡូម៉ែត្រ) ហើយតាំងគុះឲ្យលីប៉ោនាំទាហាន ៣ ម៉ឺន ចេញទៅតាំងបន្ទាយធំក្រៅកំពែងគយ ។

សេះបំរើដឹងការណ៍ ក៏យកសេចក្តីទៅជំរាបអ្នកសៀវ ៗ ប្រឹក្សានឹងចៅហ្វាយខែត្រទាំងពួងថា តាំងគុះលើកទ័ពចេញមកតាំងបន្ទាយនៅគយហៅលោកួន ឥឡូវនេះយើងនឹងគិតប្រការម្តេច ៗ ចូចឆ្លើយថា ដែលតាំងគុះលើកទ័ពចេញមកតាំងនៅក្រៅកំពែងនោះ ប្រាថ្នានឹងស្ទាក់ស្កាត់

ដើម្បីទុក, បើដូច្នេះ យើងត្រូវបែងនាយទ័ពនាយកងទាំងពួង ម្នាក់១ចំណែក លើកទៅវាយទ័ពគាំងតុះកុំឲ្យគាំងនៅបាន ។ អ្នកសៀវ ស្តាប់យល់ត្រូវ ទើបចាត់ឲ្យអង់ខង់ ១ តៀវប៉ៅ ១ ហ៊ោស៊ុន ១ អ្នកអ៊ុយ ១ ខុងឡេង ១ តៀវអៀង ១ តោកៀម ១ កងស៊ុនចាន់ ១ ឃុំនាំទាហានម្នាក់ ១ ចំណែកលើកចេញទៅ ។ ឯចូជូដាមេទ័ពល្បាត ចាំយកដំណឹងល្អអាក្រក់មកពន្យល់ឲ្យនាយទ័ពនាយកងទាំងពួង ។

ខណៈនោះ អង់ខង់បានលើកទាហានទៅដល់គយហៅលោកួនមុន គេ ។ ឯលីប៉ោដឹងការណ៍ក៏លើកទាហានឯក ៣ ពាន់ចេញតយុទ្ធនឹង អង់ខង់ៗ ក៏រៀបពលតាំងជាបែកធ្នូង-ស្តាំ ហើយបរសេះចេញទៅឈរ មុខទាហានទាំងពួង, លុះក្រឡេកទៅឃើញលីប៉ោ តែងខ្លួនប្រាណ ហ៊ុំហាក្នុងក្បួនសង្គ្រាមកាន់លំពែងជិះសេះដូច្នោះ ក៏គិតថា លីប៉ោនេះរូប រាងសមជាទាហានសេះណាស់ ទើបស្រែកប្រាប់ទាហានថា នរណា អាចនឹងយកអាសាចេញទៅតទល់នឹងលីប៉ោបាន? ។ ហង់យ៉ុកជាទាហាន ឯករបស់អង់ខង់ឆ្លើយសុំទទួលអាសា ហើយឡើងសេះកាន់លំពែងចេញ តយុទ្ធនឹងលីប៉ោបាន ៥ ក្បួន, លីប៉ោយកលំពែងចាក់ហង់យ៉ុកធ្លាក់ពីលើ សេះស្លាប់, ហើយលិប៉ោនឹងទាហានទាំងពួងក៏កំលំពែងដេញចាក់កាប់ សម្លាប់កងទ័ពហង់យ៉ុកជាប្រចំបុល, ទាហានទាំងនោះក៏វិនាសស្លាប់បែក បាក់អស់ទៅ ។ ទទួលតៀវម៉ៅនឹងអ្នកចាយលើកទាហានពាក់ព័ន្ធចូល

មកទៀត លុះឃើញកងទ័ពអង់ខងបែកមក ក៏បរពលទៅ ៗ លីប៉ៅឃើញទ័ពណុនបញ្ចូនចូលមកទៀត ក៏លើកទាហានត្រឡប់ចូលបន្ទាយ ឯអង់ខងនឹងតៀវប៉ៅ, អួនអ៊ុយឃើញដូច្នោះ ក៏បន្ថយទាហានមកតាំងបន្ទាយនៅជិតនឹងបន្ទាយលីប៉ៅ ប្រមាណ ៣០ សិន (១២០០ម). អង់ខងត្រួតរាប់ពលមើល ក៏ឃើញបាត់ខ្វាត់ទាហានជាច្រើន ៗ

ខណៈនោះ នាយទ័ពទាំង ៩ កង បានលើកពលមកដល់តាំងបន្ទាយនៅជាមួយគ្នា, ដល់ពេលព្រឹកឡើង នាយទ័ពទាំង ៨ នាក់ប្រឹក្សាគ្នាថា លីប៉ៅមានកំឡាំងខ្លាំងពូកែណាស់ នរណានឹងមានប៉ុនដៃចេញទៅច្បាំងនឹងលីប៉ៅបាន ៗ កាលប្រឹក្សាមិនទាន់ផុតសំដី ទទួលសេះបំរើមកប្រាប់ថា ឥឡូវនេះ លីប៉ៅលើកពលមកតាំងជាក្បួនទ័ពនៅមុខបន្ទាយហើយ នាយទ័ពទាំង ៨ ឮដូច្នោះ ក៏ឡើងមើលលើខ្នងបន្ទាយ ឃើញពួកទាហានលីប៉ៅរកាំភ្លៀវក្លាហោករញ្ជៀវគឹកកងជាច្រើនណាស់ ៗ ខណៈនោះមានទាហានតៀវអៀងឈ្មោះបកស៊ុន ជិះសេះកាំលំពែងចេញទៅប្រយុទ្ធគ្នានឹងលីប៉ៅ ៗ ចាក់ត្រូវបកស៊ុនធ្លាក់ពីលើសេះស្លាប់ ៗ នាយទ័ពទាំង ៨ ឃើញដូច្នោះក៏ភ័យស្លុតទាំងអស់គ្នា, ឈ្មោះប៊ូអានកុកទាហានឯកខុងឡេងក៏ឡើងសេះកាន់ដំបងដែកធំចេញទៅតយុទ្ធនឹងលីប៉ៅទៀត, លីប៉ៅក៏ចូលទទួលតគ្នាបាន ១២ ក្ងង លីប៉ៅវាត់នឹងលំពែងត្រូវដៃប៊ូអានកុកដាច់ជា ២ ដំបងដែកក៏ខ្ទាតធ្លាក់ទៅ, ប៊ូអានកុកញាក់សេះបំបាយរត់ថយក្រោយមក

វិញ ៗ នាយទ័ព ៨ នាក់ក្រឡេកឃើញក៏ចុះពីលើខ្នងបន្ទាយ ហើយបរពលចូលគប្បាំងនឹងលីប៉ោ ៗ ប៉ូអានគុកត្រឡប់ចូលបន្ទាយបានហើយ ប្រឹក្សាគ្នាថា លីប៉ោនេះចេញធ្វើការចម្បាំងខ្លាំងពូកែណាស់ បើនឹងនៅតស្រ្គាមឃើញមិនងាយនឹងយកជ័យជំនះបាន អ្នកឯណានឹងគិតឃើញប្រការដូចម្តេចខ្លះ? ៗ ប៉ូធូជ័យថា ចាំបកសំបុត្រប្តឹងទៅដល់អ្នួនសៀវឡៀងជាប, វេលានោះ នាយទ័ពទាំងពួងក៏ប្រឹក្សាគ្នាថា នរណាចេះគិតកលសឹកដូចម្តេចខ្លះ ដើម្បីនឹងយកខ្លួនលីប៉ោឲ្យបាន បើបានលីប៉ោហើយគង់នឹងបានខ្លួនតាំងតុះដោយងាយ ៗ

ខណៈនោះ សេះបំរើចូលមកប្រាប់នាយទ័ពទាំង៨គងថា លីប៉ោលើកទាហានមកតាំងនៅមុខបន្ទាយទៀតហើយ ៗ នាយទ័ពទាំង ៨ កងក៏ចាត់ចែងទាហានលើកចេញទៅស្រែកជេរគ្នា, ឧឡុកគង់ស៊ុនចានជិះសេះកាន់លំពែងចូលទៅតយុទ្ធនឹងលីប៉ោបាន១០ក្បួន, លីប៉ោនោះជិះសេះដែលមានថ្មីជើងពូកែណាស់ឈ្មោះសេកទៅវ៉, គង់ស៊ុនចានអស់កំឡាំងណាស់ក្រឡះញាក់សេះថយរត់, លីប៉ោក៏ដេញតាមប្រកិតពីក្រោយលុះដល់ជិតក៏លើកលំពែងនឹងចាក់, ឧឡុលតៀវហ៊ុយបរសេះស្ទុះមកស្ទាក់ពីមុខជាប់ ហើយស្រែកសន្ធាប់ដោយសំឡេងខ្លាំង, សេះលីប៉ោក៏យកតាំងស្ទុះថយក្រោយភ្នាត់ជើងជាច្រើនជំហាន, តៀវហ៊ុយកែកែស្រែកជេរបំពានថា អាកូន ៣ ឪពុក អញមកនឹងច្បាំងជង ហេតុម្តេចអាឯងញាក់សេះវេះរត់

ថយទៅវិញ លីប៉ោត្រូវទីងណាសក៏ញាក់សេះចូលតយុទ្ធនឹងទៀវហ៊ុយបាន ៥០ ក្បួន មិនទាន់បាញ់ឈ្នះ, គួនអ៊ូឃើញកម្លាំងទៀវហ៊ុយទន់ជាងលីប៉ោ ក៏បរសេះចូលទៅតយុទ្ធនឹងលីប៉ោទៀតបាន ៣០ ក្បួន, ឡៅពីក៏បរសេះកាន់គ្រឿងដៃទាំងសងខាងចូលទៅជួយ ៗ ខណៈនោះសេះឡៅពី, គួនអ៊ូ, ទៀវហ៊ុយ ចោមព័ទ្ធសេះលីប៉ោជា ៣ ជ្រុង, លីប៉ោក៏តាំងតែប្រយុទ្ធដោយគុណអាវុធការពារខ្លួនទាំងសងខាង លុះឃើញប្រឡោះក៏ទៅចាក់ឡៅពីនឹងលំពែង, ឡៅពីយកគ្រឿងកាត់ដាប់ ហើយបរសេះសន្ទាប់ចូលទៅនឹងចាក់លីប៉ោៗ ឃើញស្មៀតអាវុធព័ទ្ធជុំខ្លួនដូច្នោះ ក៏បរសេះស្ទុះទំលុះចេញបាន ហើយនាំទាហានចូលបន្ទាយហៅលោកួន ៗ

ឯឡៅពី, គួនអ៊ូ, ទៀវហ៊ុយ នឹងនាយទ័ពទាំង៨កងនាំពលទាហានលើកតាមទៅដល់ទល់នឹងកំពែងបន្ទាយ ឲ្យទាហានរាយទំលាយជុំវិញ ៗ លីប៉ោឡើងទៅនៅលើជើងបន្ទាយ ហើយឲ្យពលទាហានបាញ់នឹងធ្នូចោលដុំថ្មចុះមកព្រោងព្រាតហាក់បីដូចគ្រាប់ភ្លៀង ៗ នាយទ័ពទាំងពួងឃើញថានឹងរាយរំលំមិនបែក ក៏លើកទាហានថយចូលបន្ទាយវិញ ហើយតែងសេចក្តីសំបុត្របកប្តឹង ទៅដល់អួនសៀវ ៗ ដឹងសេចក្តីក៏មានចិត្តសោមនស្សត្រេកអរណាស់ ទើបចាត់សំបុត្រទៅឲ្យស៊ុនកៀនស្រួតលើកទ័ពចូលមកខ្ទប់រាយបន្ទាយលីស៊ុយកួនឲ្យបាន ៗ ឯស៊ុនកៀនបានទទួលសំបុត្រដឹងសេចក្តីហើយ ក៏ដឹងថាមានមនុស្សព្រោះញ៉ង់អ៊ួនស៊ុតមិន

ឲ្យបញ្ជូនស្បៀងអាហារទៅឲ្យ, ទើបចាត់ទាហានឲ្យនៅរក្សាបន្ទាយ ខ្លួនក៏នាំសៀវភៅទឹងអ៊ុយកាយទៅរកអ្នកស៊ុតជានាយទ័ពណហ្គូន ៗ ស៊ុនកៀននិយាយនឹងអ្នកស៊ុតថា តាំងតុះធ្វើការអាក្រក់ជាសត្រូវក្បត់ផែនដី ហើយតាំងខ្លួនជាធំ មិនមែនមកធ្វើដល់ខ្លួនយើងឲ្យវិនាសអ្វីក៏ទេ ដែលយើងខំឧហាតមកធ្វើការ ដោយនឿយព្រួយលំបាកជាមួយនឹងអ្នកសៀវគ្រានេះ ព្រោះតាំងចិត្តជាសុចរិតត្រង់នឹងផែនដី ហើយដើម្បីនឹងរំលាងតាំងតុះដែលសម្លាប់អ្នកងុយដែលជាម្ចាស់នោះចេញផង យើងក៏ត្រាវង គាប់រំសេវព្រួញនឹងគ្រឿងអាវុធមិនគិតសេចក្ដីស្លាប់ យើងឲ្យដំណឹងប្រាប់អ្នកឲ្យបញ្ជូនស្បៀងអាហារទៅឲ្យសេនាទាហាន ហេតុម្ដេចអ្នកមានចិត្តប្រុស្សាមិនចាត់ការឲ្យយើងតាមសុំ ខ្លួនអ្នកធ្វើជាធំហើយមកស្ដាប់ពាក្យមនុស្សញុះញង់ដូច្នេះមិនគួរការ ដែលអ្នកបង្អង់ស្បៀងអាហារសេនាទាហានវេលានេះ បានជាយើងត្រូវបរាជ័យដល់បច្ចាមិត្រ គួរឲ្យយើងឈឺចិត្តទោមនស្សនឹងអ្នកខ្លាំងណាស់ ៗ

អ្នកស៊ុតបានឮសំដីស៊ុនកៀននិយាយប្រៀបប្រាយដូច្នោះ ក៏មានសេចក្ដីអៀនខ្មាសណាស់ ទើបឲ្យយកខ្លួនទាហានដែលញុះញង់មិនឲ្យជូនស្បៀងអាហារនោះទៅពិឃាតជីវិតចំពោះមុខស៊ុនកៀន ៗ ខណៈនោះសេះបំរើនាក្នុងបន្ទាយស៊ុនកៀនមកឲ្យដំណឹងថា ឥឡូវនេះលីឈុយជិះសេះចេញមកពីបន្ទាយអ៊ីស៊ុយក្នុងថានឹងមករកលោក ៗ ស៊ុនកៀនបាន

ស្ដាប់គំលាអួនស៊ុតត្រឡប់ទៅបន្ទាយ ហើយឲ្យគេខ្ញូនលីឈុយចូលមកជួប ក៏សួរថា អ្នកមកនេះមានការអ្វី? ។ លីឈុយឆ្លើយថា មហាឧបរាជឲ្យខ្ញុំមកនិយាយប្រាប់អស់ទាំងចៅហ្វាយខែត្រ ដែលគប់គិតគ្នាមកធ្វើការសង្គ្រាមទាំងនេះ ឯមហាឧបរាជនឹងបានកោតញញើតខ្លាចអ្នកឯណាក៏ទេ គិតនឹងឲ្យចាប់សម្លាប់ចេញទាំងអស់ តែឥឡូវទ្រង់មានមេត្តាដល់អ្នកតែមួយនឹងបណ្ដោយឲ្យស្លាប់ជាមួយនឹងគេក៏មិនគួរសោះ បើនឹងឲ្យអ្នកដទៃមកចរចាជាមួយនឹងអ្នកពីការនេះទៅ ក្រែងអ្នកសំគាល់ថាជាកិច្ចបញ្ចុះបញ្ចូល ហេតុនេះបានជាមហាឧបរាជចាត់ឲ្យខ្ញុំមកហាមឃាត់អ្នក កុំឲ្យចូលដៃគិតជាមួយនឹងចៅហ្វាយខែត្រទាំងពួង ព្រោះមហាឧបរាជប្រុងនឹងលើកកូនក្រមុំផ្សំផ្គុំនឹងស៊ុនសេកជាកូនអ្នក នឹងបានជាមេត្រីរាប់អានគ្នាទៅ ។

ស៊ុនកៀនបានស្ដាប់ដូច្នោះក៏ទាស់ចិត្តខ្លាំង តាំងតែស្រែកគំរាមគំហក ហើយថា អាតាំងតុះនោះជាមនុស្សក្បត់ផែនដីទាំងមូល ក្ដៅរំដួលគ្រប់ដើមស្មៅនូវដើមឈើព្រៃទាំងអស់ យើងរិះគិតគ្នានឹងប្រហារវាចេញ ទើបកេណ្ឌកងសេនាយោធាលើកមកនេះ បើចាប់បានខ្លួនវាវេលាណាត្រូវប្រហារឲ្យអស់ ៧ ជួរគោត្រ ទើបអាណាប្រជានុរាស្ត្រទាំងពួងនឹងបានសេចក្ដីសុខក្សេមក្សាន្ត ដែលតាំងតុះនឹងលើកកូនក្រមុំមកឲ្យជាភរិយាស៊ុនសេកកូនយើង យកយើងធ្វើជាជន្ទល់នឹងតាំងតុះសត្រូវរាជសម្បត្តិនោះ យើងមានសេចក្ដីអៀនខ្មាសពន់ពេកណាស់, មួយទៀតទោសដែល

អ្នកចេញមកនិយាយបញ្ចុះបញ្ចូលយើងនោះ យើងលើកទោសគ្រានេះម្តង ចុះ អ្នកប្រុសត្រូវតែឡប់ចូលទៅបបួលពលទាហានទាំងពួងឲ្យចូលមកជាចិត្តមួយនឹងយើង ត្រូវបើកទ្វារបន្ទាយចាំទទួលយើងចុះ យើងនឹងលើកទាហានចូលទៅចាប់តាំងគុះសម្លាប់ចេញ បើអ្នកនឹងទាហានទាំងពួងមិនធ្វើតាមយើងពន្យល់ដូច្នេះទេ កាលណាយើងលើកទៅកាប់យកស្រុកបាន យើងត្រូវប្រហារជីវិតឲ្យអស់មិនឲ្យសល់ ។ លីឈុយបានស្តាប់ក៏ស្មុគចិត្តគិតខ្លាច ហើយលាស៊ុនកៀនស្រុកតែឡប់ចូលទៅប្រាប់តាំងគុះ។ បានស្តាប់ក៏ខឹងណាស់ ទើបប្រឹក្សានឹងលីយូចា ដែលយើងនឹងទៅបញ្ចុះបញ្ចូលស៊ុនកៀនមិនព្រមចូលចិត្តនឹងយើងនោះ អ្នកនឹងឃើញប្រការដូចម្តេច? ។ លីយូជ្វេយចា ដែលលីប៉ោបង់ប្រៀបគ្រានេះ ទាហានទាំងពួងក៏មានតែភពចិត្តចយចុះ សុំឲ្យលោកលើកទាហានចូលទៅក្រុងសំន ហើយអញ្ជើញព្រះចៅហៀនតេទៅប្រចាំបង្ក្រុងកៀងហ័ន ព្រោះខ្ញុំបានឮកូនក្មេងស្រុកប្រៀងចំនុកភ្លេងថា "តង់ចៅអ៊ុតកោហ័ន បែរចៅអ៊ុតកោហ័ន ឡុកចៅឃីបកៀងហ័នហង់ កោប៊ឈុល័ន" ប្រែថា "ទិសឯលិចមានស្រុកកៀងហ័ន ១ ទិសឯកើតក៏មានស្រុក បើប្រែសហោលចូលក្នុងស្រុកកៀងហ័នហើយ ក៏មិនមានភ័យអន្តរាយឡើយ" ខ្ញុំបានគិតឃើញក្នុងពាក្យភ្លេងនោះថា ពីដើមព្រះចៅហ័នកោចោបានកសាងព្រះរាជដានីនៅស្រុកកៀងហ័ន ហើយមានព្រះមហាក្សត្រ

សោយរាជសម្បត្តិត ៗ គ្នាមកបាន ១២ ព្រះអង្គ, ក្រោយនោះព្រះចៅហ៊ានកង់ប៊ូបានកសាងព្រះរាជធានីនៅស្រុកឡង់អៀងវិញ មានព្រះមហាក្សត្រសោយរាជសម្បត្តិជាលំដាប់គ្នាមក លុះដល់ព្រះចៅហៀនពេមាន ១២ ព្រះអង្គដែរ ខ្ញុំឃើញថាពូជព្រះរាជវង្សព្រះចៅហ៊ានកង់ប៊ូនឹងសាបសូន្យគ្រានេះហើយ រាជសម្បត្តិនោះគង់នឹងធ្លាក់បានមកលោកជាប្រាកដ បើអ្នកបានទៅកសាងព្រះរាជធានីនៅស្រុកតៀងហ៊ានវេលាណា ក៏នឹងមិនមានកើតភ័យអន្តរាយអ្វីឡើយ ៗ តាំងគុះបានស្តាប់ហើយក៏មានសេចក្តីត្រេកអរជាអនេក ហើយនិយាយនឹងលីយូថា ដែលអ្នកអធិប្បាយឲ្យយើងស្តាប់វេលានេះ យើងចូលចិត្តគិតឃើញត្រូវ, ថាហើយក៏លើកទ័ពត្រឡប់ទៅស្រុកក្រុង ៗ លុះវេលាព្រឹកភ្លឺស្វាងឡើង តាំងគុះឲ្យប្រជុំនាម៉ឺនមុខមន្ត្រីតូចធំមកព្រមគ្នាក្នុងទីគាល់ ហើយនិយាយថា យើងមើលក្នុងតម្រាឃើញថាស្រុកឡង់អៀងដែលនៅខាងទិសឯកើត នឹងរៀវពេយសាបសូន្យហើយ ស្រុកទិសឯលិចនឹងវឌ្ឍនាចំរើនរុងរឿងទៅខាងមុខ យើងនឹងអញ្ជើញព្រះចៅហៀនពេ ស្តេចទៅសាងព្រះរាជធានីនៅក្នុងស្រុកតៀងហ៊ាន បើដូច្នេះត្រូវអស់អ្នក លំគ្នាលើកគ្រប់គ្រួទៅតាម សាងវាំងលំនៅ ៗ ទីនោះឯង ៗ

អៀវតៀវឆ្លើយថា ឯស្រុកឡង់អៀងនេះព្រះចៅហ៊ានកង់ប៊ូសាងក្រុងសោយរាជសម្បត្តិមកជាយូរហើយ មានព្រះមហាក្សត្រិយ៍ដល់ ១២.

ព្រះអង្គ ដែលលោកនឹងឲ្យលះបង់ស្រុកនេះ លើកគ្នាទៅនៅស្រុកតៀងហ័ននោះ ខ្ញុំឃើញថាអាណាខេត្រនឹងកើតចលាចល បណ្ដាប្រជាជនក៏នឹងបានសេចក្ដីក្ដៅក្រហាយ ដូចមានពាក្យបុរាណថា "ធម្មតាផ្ទះដែលនឹងរើរុះនោះងាយណាស់ លុះនឹងសង់ឡើងវិញក៏បានដោយក្រ" បើមិនស្ដាប់ពាក្យខ្ញុំខំតែលើកទៅតាំងនៅស្រុកតៀងហ័នហើយ បណ្ដារាស្ត្រនឹងបានសេចក្ដីភ្ញាក់ផ្អើលបែកខ្ចាត់ខ្ចាយអស់ លុះនឹងកៀរប្រមូលឲ្យមូលមកវិញបាន ដោយក្រណាស់ ដែលខ្ញុំដំរាបទាំងនេះ សូមលោកត្រិះរិះមើលតាមសមគួរ ។

តាំងតុះបានឮក៏ខឹងខ្លាំងណាស់ទើបនិយាយថា ខ្លួនយើងជាមហាឧបរាជនឹងបង្គាប់បញ្ជាការអ្វីក៏ជាសិទ្ធិប្រាកដ យើងមើលតម្រាឃើញថានឹងកើតមានអន្តរាយទើបបានជានិយាយពន្យល់ដូច្នេះ ហេតុអ្វីខ្លួនមកចេះឃាត់ឃាំងទទឹងនឹងពាក្យរបស់យើង ។

អ៊ុយអ៊ិនជូនឆ្លើយឡើងថា ដែលអៀរពៀរទទឹងទាស់នោះត្រូវណាស់ ព្រោះកាលអង់ម៉ាំងជាសត្រូវក្បត់ដណ្ដើមយករាជសម្បត្តិ ហើយដុតស្រុកវិនាសអស់ទៅ ស្រុកនោះក៏ទៅជាព្រៃផ្សៃ ដែលលោកនឹងលះបង់ស្រុកនេះហើយទៅយកព្រៃធ្វើស្រុកនោះខ្ញុំឃើញមិនសមគួរ ។

តាំងតុះតបថា យើងឃើញខាងទិសឯកើតៗចលាចលដោយពួកចោរធ្វើឲ្យអន្តរាយផ្សេងៗមកជាច្រើនគ្រាហើយ ខាងស្រុកតៀងហ័ននោះ

ពីដើមក៏ជាទីក្រុងដែរ យើងឃើញគួរសម ដោយមានភ្នំនឹងថ្មសិលាគួរទីង ចាត់ការរៀបស្រុកបានមិនលើសពី ១ ខែ ក៏នឹងជាសុខសប្បាយជាមួយគ្នា ហេតុនេះកុំបីអ្នកទាំងពួងទទឹងទាស់តទៅទៀតឡើយ ។

ស៊ុនសង់ឆ្លើយឃាត់តាំងតុៈដូចពាក្យអ៊ុយអួន តាំងតុៈឆ្លើយថា យើងនឹងទំនុកបំរុងរាជសម្បត្តិនេះជាការធំមាំមួនណាស់ ឧបមាដូចតាសរំលើងគល់ឈើធ្វើស្រែចម្ការ បើនឹងស្តាយដើមឈើ កាលណានឹងបានស្រូវស៊ី, ចាហើយតាំងតុៈក៏ឲ្យដកហូតងារ អៀវពៀវ, អ៊ុយអួន នឹងស៊ុនសង់ចេញចាកតំណែងមន្ត្រីរាជការ ហើយតាំងតុៈឯងឡើងជិះរទេះនឹងទៅកាន់វាំលំនៅ លុះចេញទៅដល់ក្រៅទ្វារព្រះរាជវាំង ប្រទះអៀវពៀវនឹងងៅខេងចូលមកគំនាប់ពីមុខរទេះ តាំងតុៈសួរថា អ្នកទាំង ២ មានការមករកអ្វី? ។ អៀវពៀវនឹងងៅខេងជំរាបថា យើងខ្ញុំបានឮកិត្តិសព្ទថា លោកនឹងលះបង់ចោលស្រុកនេះទៅសាងក្រុងនៅស្រុកតៀវហ័ន យើងខ្ញុំយល់ឃើញមិនសមគួរ ទើបចូលមកជំរាបឃាត់លោក ។ តាំងតុៈបានស្តាប់ក៏ក្រេវក្រោធហើយថា ឯងទាំង ២ រូបនេះកាលពីពេលមុន បាននិយាយឲ្យយើងតាំងអួនសៀវជាចៅហ្វាយខែត្រ យើងបានធ្វើតាមសំដីឯងទាំង ២ នាក់ តឡូវនេះអួនសៀវត្រឡប់មកប្រទុស្តរាយនឹងយើងវិញ ប្រហែលជាគាត់ឯងទាំង២នាក់ចូលគំនិតគិតធ្វើកលជាមួយនឹងអួនសៀវពិតមែន, ចាះហើយក៏បង្គាប់ពេជ្ឈឃាដឲ្យចាប់អៀវពៀវនឹងងៅខេង ទៅសម្លាប់ក្នុងពេលនោះ

ហើយតាំងគុះក៏ហួសទៅដល់ទីលំនៅ ទើបកំណត់ពេលដែលនឹងលើកគ្រប់គ្រួសារទៅតាំងរាំងកំពែងនៅស្រុកតៀវហ៊ាន ។ ពេលនោះលីយូជំ-ភបថា ដែលលោកនឹងលើកគ្រប់គ្រួសារទៅសាងទីក្រុងនោះ ស្បៀងអាហារនឹងមាសប្រាក់ក្នុងផ្ទៃព្រះឃ្លាំងមាននៅច្រើនណាស់ ឃើញថាការមិនគ្រប់គ្រាន់, នៅក្នុងស្រុកឡូកអៀងនេះមានសេដ្ឋីគហបតីដែលមានភោគសម្ប័ទក៏ច្រើន សូមឲ្យលោកទៅរឹបជាន់រើយកមកដាក់ឃ្លាំងឲ្យហើយ ទើបនឹងគិតធ្វើការនេះបានដោយងាយ, មួយទៀតបណ្ដាប័ក្ខពួកក្អួនសៀវដែលនៅក្នុងស្រុកក្រុងនេះក៏ច្រើន សូមឲ្យលោកចាប់សម្លាប់ចេញឲ្យអស់ ហើយរឹបយកទ្រព្យរបស់មកដាក់ឃ្លាំងកុំឲ្យសល់ ៗ តាំងគុះស្ដាប់យល់ត្រូវក៏ចាត់សេនាទាហាន ៥.០០០ ឲ្យទៅសង្កត់សង្កិនពួកអាណាប្រជាជនដែលមានទ្រព្យសម្បត្តិមាសប្រាក់នោះយកមកទាំងអស់, ឯម្ចាស់របស់ក៏ឲ្យចាប់ខ្នះមកបង្ខុកហើយឲ្យយកទង់ដោតដាក់លើក្បាលសរសេរអក្សរ ២ តួថាពួកក្បត់ ហើយនាំទៅប្រហារជីវិតទាំងអស់ ក្នុងពេលនេះតាំងគុះបានទ្រព្យសម្បត្តិច្រើន ៗ លុះស្រេចការហើយតាំងគុះក៏ឲ្យលីឈុយ, គុយគី បណ្ដាញបំបរអាណាប្រជានុរាស្ត្រក្នុងស្រុកឡូកអៀង ឡើងទៅនៅក្នុងស្រុកតៀវហ៊ានមិនមានសល់ដល់ម្នាក់ ។

កាលលីឈុយ, គុយគី បណ្ដាញបំបរអាណាប្រជានុរាស្ត្រទៅនោះ មនុស្សអ្នកនគរទាំងប្រុសទាំងស្រីក្មេងចាស់ប្រហែល ៦០០ ម៉ឺនឬ ៧០០

ម៉ឺន នឹងទាហានតាំងតុះក៏លើកប្រពាក់ប្រពូនទៅជាកង ១ មនុស្សផង ប្រៀតប្រៀតជាន់គ្នាស្លាប់ក៏មាន ទាហានខ្លះក៏មកដណ្ដើមយកទ្រព្យរបស់បណ្ដារាស្ត្រ ខ្លះក៏អូសកន្ទ្រាក់យកភរិយាបុត្រគេទៅធ្វើបរទារកម្មតាមអំពើចិត្តឥតកោតខ្លាច រាស្ត្រទាំងនោះសឹងលុះដោយអំណាចដែលគេគំហកកំហែងជាចលាចល មនុស្សទាំងក្មេងទាំងចាស់ខ្លះថ្ងូញយំតាមផ្លូវទៅ, មុខគួរឲ្យករុណាអាធ័មពន់ពេក ។

ឯតាំងតុះទៀមការទាំងអស់ជាស្រេចហើយ ក៏ឲ្យទាហានយកភ្លើងដុតគុជព្រះរាជវាំងនឹងផ្ទះសំបែង បណ្ដាដែលមានក្នុងស្រុកឡូកអៀងនោះទេះទាំងអស់ ហើយឲ្យលើបង្ខំពលទាហានទៅជីករំលំរំលើងព្រះបរម-សពនៃព្រះមហាក្សត្រពីបុរាណដែលមានផ្នូរបញ្ចុះទុកតមក ហើយកកាយរើយកមាសប្រាក់ដែលនៅជាមួយនឹងសពនោះជាច្រើន, ទាហានខ្លះក៏បន្ទំជីកគាស់កកាយយកទ្រព្យរបស់ក្នុងសព របស់អាណាប្រជានុរាស្ត្រមកជាប្រយោជន៍រៀងខ្លួន, តាំងតុះក៏ឲ្យដញ្ជូនទ្រព្យទាំងនោះផ្ទុកលើរទេះជាងពាន់បរសេះទឹកលានទាំងប្រចុះចេញទៅ ហើយក៏អញ្ជើញព្រះចៅហៀនតេស្ដេចទៅជាមួយនឹងស្រីស្នំក្រម្ការនឹងខ្ញុំរាជការទាំងពួង ។

វេលានោះតៀវរ៉ឹមដែលចេញទៅតាំងបន្ទាយនៅគយគីស៊ុយគួនជាមួយនឹងហួយុនដែលស្លាប់ ហើយនឹងទាហានដែលនៅរក្សាគយ:ហាក់

លោគួននោះ លុះដឹងថាតាំងតុះបោលស្រុកឡុកអៀងហើយ, តៀវង៉ិមក៏នាំទាហានទាំងអស់នោះទៅតាមតាំងតុះ ។

ឯស៊ិនគៀន កាលឃើញបន្ទាយគីស៊ុយគួនស្ងាត់ឥតមនុស្សម្នាដូច្នោះ ក៏ពិគ្រោះនឹងនាយទ័ពទាំង ៨ ហើយនឹងឡេវពី, គួនអ៊ូ, តៀវហ៊ុយ ដើម្បីស្តាប់ការ លុះដឹងថាតាំងតុះលើកពលទាហានទៅអស់ហើយ ក៏បរពលចូលទៅក្នុងស្រុកឡុកអៀង កាលចូលដល់ក៏ក្រឡេកទៅឃើញភ្លើងកំពុងឆេះផ្ទះសំបែង ពេញក្នុងស្រុកនោះ នឹងរកមនុស្សក៏មិនឃើញមានសោះ នោះនាយទ័ពនាយកងទាំងពួង ក៏ចាត់ឲ្យទាហានចូលលត់ភ្លើងរលត់អស់ហើយក៏តាំងទ័ពនៅទីនោះ ។

ចូចូដំរាបអ្នកសៀវថា តាំងតុឲ្យដុតស្រុកបោលបានលើកទាហានរត់ទៅខាងទិសឯលិចហើយ ឯព្រះបាទហៀនតេសោតយើងមិនទាន់ដឹងជាក់ច្បាស់ជាល្អឬអាក្រក់ វេលានេះអាណាប្រជានុរាស្ត្រកំពុងមានសេចក្តីក្តៅក្រហាយវរវិកណាស់ បើដូច្នេះត្រូវតែយើងលើកកងទ័ពទៅតាមដើម្បីនឹងចាប់តាំងតុបានដោយងាយ ហេតុម្តេចលោកនៅស្ងៀមដូច្នេះ? ។

- អ្នកសៀវនឹងចៅហ្វាយខេត្តទាំងពួងឆ្លើយថា ទាហានយើងកំពុងនឿយហត់ណាស់ ចាំឈប់សម្រាកកំឡាំងបន្តិចសិនសឹមគិតការលើកតាមទៅ ។ ចូចូបានស្តាប់ហើយក៏នឹកតែក្នុងចិត្តថា ការដែលមករួមគំនិត

គិតធ្វើជាមួយនឹងចៅហ្វាយខែត្រទាំងអស់នេះជាការធំមាំមួនណាស់ តែបំដួចជាទៅគិតគ្នាជាមួយនឹងក្មេងគង្វាលគោ, គិតដូច្នោះហើយក៏រៀបចាត់តែងទាហានដែលជាបក្ខពួករបស់ខ្លួនបានប្រហែលមួយម៉ឺនប្លាយ ហើយក៏នាំហៃហ្ទុន, ហៃហ្វៀន, ចៅហាង, ចៅយ៉ិន, លីទៀន, ផាក់ជិន នឹងទាហានទាំងពួងស្រុតលើកតាមគាំងតុះទាំងថ្ងៃទាំងយប់ ។

ឯគាំងតុះកាលលើកពលទៅដល់ស្រុកអេងយ៉ុង នោះស៊ុំអេងជាចៅហ្វាយស្រុកដឹងដំណឹងក៏ចេញមកទទួលគាំងតុះ ។ លីយូជំរាបគាំងតុះថាយើងលើកពលចេញពីស្រុកក្រុងមកគ្រានេះ ខ្លាចក្រែងពួកសត្រូវនឹងលើកតាមមកពីក្រោយ បើពួកយើងនឹងតទល់មិនបាន យើញនឹងខូចការធំ ដូច្នេះសូមឲ្យស៊ុំអេងឃុំនាំទាហានទៅបង្កប់នៅលើភ្នំចំដើមផ្លូវចុះ បើកងទ័ពទាំង ៨ ស្រុកលើកមកតាមមែន ក៏ឲ្យស៊ុំអេងចេញតទល់ជាមុន ប្រ-ស៊ិនកងទ័ពគេចំលាយចូលមកបានគឺនឹងកងទ័ពយើង ៗ ឲ្យស៊ុំអេងចេញវាយខ្លួនពីក្រោយថែមមកទៀត ទ័ពដែលតាមមកគង់នឹងបាញ់ប្រៀបយើងជាប្រាកដ ។ គាំងតុះបានស្ដាប់យល់ឃើញត្រូវ ទើបបង្គាប់ឲ្យស៊ុំអេងឃុំនាំទាហានលើកទៅបង្កប់លើភ្នំដើមផ្លូវនោះ ហើយឲ្យលីចុ៉ងនឹងលីឈុយ, គុយគី លើកទាហានតាមទៅដើរជាទ័ពក្បួនក្រោយ ។

(មានត)

## រឿងព្រេងក្មា

## លោកសាង សារ៉ាត

លេខានុការក្រសួងបារិញ្ញវត្ថុ ប្រែរៀបរៀង

(តមក)

# ៣ — ការកាត់សេចក្ដីកាបសាហារ

" ការណ៍កាបសាហារ ទឹកចិត្តខ្លះខ្លៅ

គេមិនបានហៅ សុភាបានពិត " ។

មានសេចក្ដីដំណាលថា កាលនោះ មានសត្វឆ្កែ ១ គូ ឈ្មោល - ញី រកស៊ីចិញ្ចឹមជីវិតនៅក្នុងព្រៃស្មសាន ដូចជាឆ្កែព្រៃ ។

លុះថ្ងៃក្រោយបន្តិចមក សត្វឆ្កែទាំងគូនោះមានកូន ៣ គឺ: ឈ្មោលមួយញីពីរ ក៏មានចិត្តពេញបរិបូណ៌ទៅដោយបីតិនឹងសោមនស្សជ្រៃក្រៃលែងចំពោះកូនទាំង ៣ នោះ ប៉ុន្តែដល់យូរទៅសត្វទាំង ២ នោះកើតមានការទាស់ទែងគ្នាឡើងក្នុងគ្រួសារ ។ ដើម្បីកុំឲ្យមានការឈ្លោះប្រកែកគ្នាជាអចិន្ត្រៃយ៍ ឆ្កែទាំងគូដែលសុទ្ធតែជាសត្វប្រាថ្នាសន្តិសុខ ក៏បានសម្រេចសេចក្ដីដោយស្រុះស្រួលគ្នាថា នឹងបែកថយចេញពីគ្នាតែរៀងខ្លួន ។

លុះកាលណាសុខចិត្តតែសព្វខ្លួនដូច្នោះហើយ សត្វទាំងគូក៏តាំងបែកមតិគ្នា (បែកកូនគ្នា) ម្នាក់យកកូនឆ្កែញីមួយ ឯចំណែកកូនឆ្កែឈ្មោលមេទឹងបានចង់បានតែសព្វខ្លួន ៗ លុះចែកគ្នាមិនដាច់ស្រេច មិនព្រមព្រៀងគ្នា ឆ្កែឈ្មោល-ញីទើបនាំគ្នាចូលទៅកាន់សំណាក់ខ្លា លុះទៅដល់ហើយអង្វរខ្លាសុំឲ្យធ្វើជាអ្នកអាជ្ញាកណ្តាលកាត់សេចក្តីឲ្យ ។ ឯសត្វខ្លាលុះបានស្តាប់សព្វសេចក្តីហើយ និយាយថា "បើដូច្នេះ អ្នកឯងមករកខ្ញុំឲ្យខ្ញុំចែកឲ្យឬយ៉ាងណា? តើប្រាកដជាចង់ឲ្យខ្ញុំចែកឲ្យមែនឬអ្វី?" ។

ថ្វីបើមានចិត្តសង្ស័យនឹងពាក្យគំរោះបន្តិចរបស់ខ្លានោះ សត្វទាំងពីរក៏នៅតែធ្វើសញ្ញាថា "បំណងរបស់យើង គឺដូច្នោះឯង" ។ ខ្លានិយាយថា "បើដូច្នោះ ខ្ញុំចែកឲ្យ" ថាហើយខ្លាក៏ឲ្យកូនឆ្កែញីមួយទៅបា មួយទៀតទៅមេ ឯកូនឆ្កែឈ្មោលដែលសល់នោះ ខ្លាក៏កាត់ជាពីរកំណាត់ចំពាក់កណ្តាលខ្លួន ហើយបោះ ១ កំណាត់ឲ្យទៅមេ ១ កំណាត់ឲ្យទៅបា ទាំងកំពុងហូរឈាមស្រោកនោះ ៗ ឯឆ្កែឈ្មោល-ញីទាំងពីរឃើញដូច្នោះ ក៏ស្រែកលូក្រលួចឡើងព្រុសួរខ្លួរខ្ញូររំពងពេញព្រៃថា "ឱលោកខ្លាមហាបពិត្រអើយ! លោកបានចែកឲ្យខ្ញុំក៏ពិតមែនហើយ ប៉ុន្តែលោកមិនគួរនឹងធ្វើទារុណកម្មយ៉ាងនេះសោះ", ថាហើយ ឆ្កែញី-ឈ្មោលក៏បោកបំណែកនៃសាច់កូនកំសត់របស់ខ្លួន ដែលប្រឡាក់សុទ្ធតែឈាមនោះទៅនឹងជើងខ្លា ហើយត្រឡប់ចូលទៅក្នុងព្រៃទាំងគូ លែងនឹកនាពីការចែក

ប៉ាក់គ្នាតទៅ ត្រឡប់ជាស្រុះស្រួលមូលមិត្តគ្នាទៅវិញ ដោយសារមានទុក្ខជាមួយគ្នានេះ ។

## ៤ – ប្រាជ្ញារបស់ទន្សាយ

"គ្មានខុនគ្មានអត់ មេត្រីប្រាកដ ឆាប់បែកឆាប់ប៉ាក់" ។

កនុងកាលដ៏កន្លងយូរអង្វែងណាស់មកហើយ នៅក្នុងនគរស្រុកសូម្ពមួយ ដែលមានទឹកហូរស្រោចពីទន្លេ ខ្ញុកង់ ( Le gange ) កាលណោះមានសត្វបបក ១ គេ ១ បានចងមេត្រីនឹងគ្នាយ៉ាងស្មោះស្ម័គ្រ ហើយរកស៊ីចិញ្ចឹមជីវិតនៅជាមួយគ្នាជានិច្ច ។ មានមួយព្រឹកនោះ ជាពេលភ្លឺច្បាស់ល្អ មិត្តទាំងពីរនាំគ្នាដើរតាមមាត់ព្រែក ដើម្បីស្វែងរកអាហារបរិភោគ, លុះដល់ថ្ងៃត្រង់ គេបាប់បានត្រីមួយយ៉ាងល្អក្នុងដើមត្រែង រួចមិត្តទាំងពីរក៏តាំងវាយចំណែកគ្នា ។ គេនិយាយថា "អញយកក្បាលនឹងពោះ" បបកឆ្លើយវិញថា "ទេ ! ឯងយកចំណែកខ្លួនដែលអញចង់បានដែរ" ។

រឿងនេះ សត្វទាំងពីរបែកគ្នាមិនដាច់ស្រេច ក៏កើតទាស់ទែងគ្នាខុសពីធម្មតារបស់ខ្លួន ទឹងខុសពីធានការសម្ពន្ធមិត្តល្អ ។ ដល់ថ្ងៃក្រោយបង្អស់ព្រោះតែការមិនព្រមព្រៀងគ្នានោះ ក៏នាំគ្នាទៅប្ដឹងទន្សាយមួយដែលមានល្បីឈ្មោះខាងគតិបណ្ឌិត គឺទន្សាយនេះហើយដែលទឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាល ។ សុភាទន្សាយ បានស្ដាប់ពាក្យពន្យល់របស់បបកនឹងគេ ហើយនិយាយដោយត្រៀមត្រិះថា

"នែបងប្អូនទាំងពីរ បងជាមិត្តភក្តិនឹងគ្នាមកយូរហើយ តើឈ្លោះប្រកែកគ្នាធ្វើអ្វី? វាមិនសមសោះ បងបានស្រឡាញ់គ្នាយ៉ាងមាំមួនតាំងពីនោះមកដល់នេះ ម្តេចក៏ឲ្យបែកគ្នាវិញបាន សព្វប៉ះរឿងបន្តិចបន្តួច រឿងនេះគេងាយនឹងសំរួលទេតើ, ហេតុដូច្នេះ ដកបណាដែលគេចាប់បានត្រីមួយ ដកបនោះគោងបែកដូចខ្ញុំបង្ហាញនេះ" ។

ទន្សាយក៏ពុះត្រីចំពាក់កណ្តាល ពីក្បាលរហូតដល់កន្ទុយ រួចហុចឲ្យទៅភេ១ចំហៀង, ចចក១ចំហៀង តាមចំណែកដែលពេញចិត្តរៀងខ្លួន ។

រឿងល្បើកនេះ សំដែងឲ្យឃើញប្រាជ្ញាដ៏វិសេសនៃពាក្យប្រៀនប្រដៅរបស់ព្រះនាងខត្តិយានី ធូដាម្នាសារី ( Thoudamna Sari ) កាលដែលព្រះនាង មានព្រះតម្រាស់ថា:

"ទោះស្តេចក្តី ទោះអភិជនក្តី ទោះចាងហ្វាងក្តី គោងតែយកទន្សាយដែលទឹងបានជាព្រះពុទ្ធង្គអនាគតជាគំរូ មិនត្រូវឲ្យបំណងទុច្ចរិតផ្សេងៗ ធុសធុលជុំវិញខ្លួនទេ, គោងឲ្យទៅម្នាក់ៗ នូវចំណែកដែលគេត្រូវបាន, គោងយកសេចក្តីសុចរិតជាប្រធាន ក្នុងការសម្រាតរបស់ខ្លួន, ជនណាដែលមិនប្រព្រឹត្តតាមសិក្ខាបទនេះទេ ជននោះមិនអាចទៅដល់លំនៅរបស់ក្រុមណាត់ ១) (Nat) ដ៏ប្រសើរឡើយ" ។ (មានត)

---

១ ក្រុមណាត់ ( Nat ) គឺក្រុមទេវតា ក្នុងរឿងព្រេងបុរាណកាលរបស់ជាតិភូមា ។

## រឿងក្មេងកំព្រា (រឿងព្រេង)

# ឃុន បរិក្សបរិភ័ណ្ឌ ឈឹម-ណាក ក្រុមពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង (តចប)

---

ថែមទាំងទឹកស្បូត្រមន្តរបៀនសិល្បសាស្ត្រ ដែលធ្លាប់ចេះធ្លាប់រៀនមក ប៉ុន្មានក៏នៅតែរមិនរួចអំពីជុបនោះ រឹតតែតឹងឡើងៗ ស្ទើរតែដាច់ខ្យល់ទឹង រកស្តីនិយាយស្ទើរតែមិនរួច ។ យក្សទើបដឹងថា ជុបក្មេងនេះពូកែមែន, បើអញមិននិយាយអង្វរឲ្យវាស្រាយជុបនេះចេញទេ ទឹងស្លាប់អសារគតការមិនខាន, ទើបនិយាយអង្វរកុមារថា "នុះលោកអើយ! កាលពីដើមខ្ញុំមើលងាយជុបលោក ដោយគិតឃើញថា មើលទៅមិនល្មមនឹងកម្លាំងខ្ញុំសោះ ហេតុតែសេចក្តីមើលងាយនេះហើយ បានជាខ្ញុំស្ទើរតែស្លាប់ខ្លួនយ៉ាងនេះ ហេតុនេះ សូមលោកអាណិតមេត្តាខ្ញុំម្តងទៅចុះ ខុសម្តងក្តីមួយថ្ងៃ សូមលោកអធ្យាស្រ័យឲ្យរស់តែជីវិតកុំឲ្យតែខ្ញុំស្លាប់" ។

ឯកុមារបានឃើញយក្សប្រមះនេះទៀលមិនរួចពីជុបរបស់ខ្លួនហើយ ថែមទាំងព្រូនិយាយអង្វរទៀត, កាំបិតនៅដៃនិយាយតៈវាទឹងយក្សវិញថា "មើចអាឯងដៀអញទេ, ឥឡូវមកធ្វើជានិយាយអង្វរ, ឯសាច់ជីវអញអាឯងស៊ីអស់ ហើយគិតនឹងស៊ីអញទៀត អាឯងច្រើមធំណាស់ អញមិនយកអង្វរអាឯងទេ, ល្ងាចនេះអញគ្មានអ្វីស៊ីសោះ ម្តងនេះអញស៊ីថ្លើមអាឯង

ហើយ, ចុះមកបង, ទៅរកកាប់ឫស្សីមកធ្វើត្រណោតដោតថ្ងើមអាខូប នេះអាំងស៊ី" ។ បងក៏ចុះពីផ្ទះមកទាំងភ័យញ័រញ័រ ដល់មកជិតប្អូនឃើញយក្សត្រូវស្ងៀម ក៏រឹតរឹងតែញាប់ញ័រ ៗ ប្អូននិយាយថា "ឈប់បង កុំញ័រចង់ស៊ីរពេក ឈប់សិន ចាំប្អូនសិន, ហៈញ័រចង់អ៊ីទៀតហើយ កុំញ័រអ៊ីពេក យើងស៊ីនៅមិនឆ្ងាញ់ទេហើមពោះពុងណាបង" ។ យក្សឮសំដីកុមារនិយាយនឹងបងដូច្នោះហើយរឹងរឹតតែភ័យស្លុតព្រលឹង ហើយនិយាយអង្វរកុមារទៀតថា "ឱលោកម្ចាស់ថ្លៃអើយ! សូមលោកអាណិតខ្ញុំយកបុណ្យម្តងនេះទៅចុះ, ខ្ញុំនឹងជូនកន្សែងបក់កន្សែងបោយមួយ ឲ្យតែលោកលែងខ្ញុំឲ្យបានរស់មានជីវិត ដ្បិតខ្ញុំជាស្តេចយក្សគ្រប់គ្រងអាណាប្រជា-រាស្ត្រ, បើលោកឲ្យខ្ញុំស្លាប់ទៅ សមជាស្រុកទេសរបស់ខ្ញុំអន្តរធានមិនខាន ទាំងកូនប្រពន្ធខ្ញុំទៀតក៏ពុំមានទីពឹង" ។ កុមារប្អូនសួរបញ្ឈាក់យក្សថា "ចុះឯងឲ្យកន្សែងបក់កន្សែងបោយដល់យើង, កន្សែងនោះបើបក់-បោយទៅអាចឲ្យសម្រេចប្រយោជន៍ដូចម្តេចខ្លះ?" ។ តាមតែលោកចង់បានអ្វី បក់មកបានតាមប្រាថ្នា បើចង់ឲ្យបាត់ទៅវិញ គ្រាន់តែបោយថាទៅវិញចុះ ក៏ស្រាប់តែបាត់អស់រលីង ៗ ប្រាកដជាឯងឲ្យយើងមែនឬ? ។ មែន ៗ ក្រែងកុហកទេដឹង? ។ មិនកុហកទេលោក ៗ បើកុហកតើឲ្យយើងធ្វើដូចម្តេច? យើងមិនទុកចិត្តទេពីព្រោះឯងជាស្តេចសោយរាជ្យ ក្រែងរួចពីកណ្តាប់ដៃយើងទៅ បបួលរេហ៍ពលមកច្បាំងនឹងយើង

វិញ? បង! យកកាំបិតមកពន្វះសាច់អាំងស៊ីសម្រន់សេចក្ដីឃ្លាន ១ ស្របក់សិន ។ បងនោះនៅតែមិនទាន់បាត់ភ័យនឹងយក្ស ។ យក្សឮកុមារតូចឲ្យបងយកកាំបិតមកពន្វះសាច់ខ្លួនដូច្នោះ ក៏ញាប់ញ័រស្ទើរតែបាត់ស្មារតី ហើយនិយាយអង្វរកុមារនោះទៀតថា " សូមតែលោកទុកជីវិតឲ្យចុះ ខ្ញុំនឹងប្រគល់រាជ្យទាំងអស់ ព្រមទាំងស្រុកសួយទាំងអម្បាលមាន ជូនលោកទៀត ខ្ញុំសូមឲ្យរួចតែខ្លួននឹងភរិយា - បុត្រី - បុត្រា ហើយនៅធ្វើជាសេនារក្សាលោកទៀត " ។ កុមារប្អូនក៏សួរបញ្ឆាក់យក្សថា " បើឯងនិយាយទៀងត្រង់មែន ណ្ហើយយើងអត់ទោសឲ្យបាន, តែយើងមិនដឹងថាឯងជាស្ដេចសោយរាជ្យនៅនគរណា ចុះធ្វើម្ដេចឲ្យយើងទៅតាមយកនគរឯងបាន? ។ ឱ! លោកមិនសល់ក្រអ៊ុំនឹងអញ្ជើញទៅឯនគរខ្ញុំនោះទេ ឲ្យតែលោកលែងខ្ញុំចុះ ខ្ញុំនឹងធ្វើតម្រុយជាលំអានរហូតដល់ទៅនគរខ្ញុំឯណោះ ។ ឯងធ្វើតម្រុយបែបណា? ។ ខ្ញុំកាប់មែកឈើស្រស់ៗហែៗ តាមផ្លូវទៅ កាលបើលោកអញ្ជើញទៅ សូមទៅតាមស្នាមមែកឈើដែលខ្ញុំកាប់នេះចុះ ។ កុមារទាំងពីរក៏ព្រមដោះយក្សចេញពីដុប ។ ឯយក្សបានរួចខ្លួនពីដុបហើយ ក៏ក្រាបថ្វាយបង្គំកុមារទាំងពីរដើរទៅនគរខ្លួនវិញ ហើយកាប់មែកឈើជាតម្រុយ ដើម្បីជាទីសំគាល់ដល់កុមារទាំងពីរប្រាណ ឥតមានកុហកភូតភរអ្វីឡើយ លុះដល់ទៅនគរហើយ ចូលទៅនិយាយប្រាប់ពួកពលសេនា យាធាទាហានដែលនៅចាំ

ក្លោងទ្វារ ទាំង ៧ ជាន់ថា "នែវ៉ើយ ថ្ងៃស្អែកនេះមានក្មេងតូច ៗ ពីរនាក់ ជាក្មេងមនុស្សលោក មកដណ្ដើមរាជ្យអញ, បើពួកឯងឃើញវាហើយ ឃាត់កុំឲ្យចូល តែកុំធ្វើទុក្ខបុកម្នេញវាឡើយ គ្រាន់តែស្រែកឃាត់ ប៉ុណ្ណោះបានហើយ ពីព្រោះក្មេងនោះតូចតែណាស់ អម្បាលអញដែល មានរិទ្ធិ មានអំណាចអាចច្បាំងដណ្ដើមយកនគរឯទៀត ៗ បានមកធ្វើជា ប្រទេសរាជទាំងប៉ុន្មាន ក៏វាជាក់ដុបអញជាប់ស្ទើរតែនឹងស្លាប់អស់សារតត ការ, តែពួកឯងកល់គ្នាឃាត់វាល្បងមើលសិនចុះ, បើវាមិនខ្លាចទេ បើក ផ្លូវឲ្យវាចូលមកចុះ" ។ យក្សបានប្រាប់គ្រប់សេនាអ្នកចាំក្លោងទ្វារទាំង៧ ជាន់សព្វគ្រប់ហើយ ក៏ចូលទៅក្នុងប្រាសាទ សំងំដេកលក់ស្រមុក កក្រើកប្រថពី ។ ឯបងប្អូនទាំងពីរក៏បណ្ដើរគ្នាទៅនគរយក្សតាមតម្រុយ មែកឈើ, លុះបានទៅដល់ហើយក៏ជួបប្រទះនឹងពួកកងទ័ពមួយកងដែល នៅចាំក្លោងទ្វារទី ៧ នោះ, កុមារបងបានឃើញយក្សច្រើនដល់ម៉្លោះ ក៏ ភិតភ័យញាប់ញ័រស្ទើរនឹងបាត់ស្មារតី, ប្អូននិយាយកម្ចាបងឡើងថា "នែ បងកុំញ័របងពេក! ឈប់កុំបងចាប់កាប់ធ្វើបាបវាឡើយ ឈប់ ៗ កុំ ៗ យើបង! ស្ទើរតែឃាត់មិនឈ្នះ ណ្ហើយកុំញ័របងពេក វាខ្លាចបងហើយ" ។ ពួកទាហានយក្ស បានឮកុមារនិយាយដូច្នោះហើយក៏ខ្លាចប្រួញខ្លួន ឥត ហ៊ានមាត់កអ្វីសោះ បើកផ្លូវឲ្យកុមារទៅដោយស្រួល រហូតដល់ទៅទ្វារ គ្រប់៧ជាន់ យក្សខ្លាចទាំងអស់ ៗ ទើបនាំបងប្អូនឡើងទៅលើប្រាសាទ

យក្ស ឃើញយក្សកំពុងដេកស្រមុកខ្ជួរប្រាសាទ ឃើញពួកស្រីស្នំ
កំពុងតែអង្គុយបក់ខាងស្ដាំមួយរយ ខាងឆ្វេងមួយរយ ។ ឯបងឃើញ
យក្សច្រើនសម្បើមណាស់ពេក ក៏ភ័យស្លុតស្មារតី, ប្អូនស្រែកហៅយក្ស
ថា នែ! តានេះក្រោកឡើង អញមកដល់ហើយ ដេកដល់ណាទៀត ” ។
យក្សឮសំឡេងកុមារតូចស្រែកហៅខ្លួន ដែលកំពុងដេកលក់ដូច្នោះ ក៏
ភ្ញាក់ដឹងខ្លួនឡើងក្រឡេកមើលទៅ ស្គាល់ជាក់ជាកុមារម្ចាស់ជុច ក៏ភិត
ភ័យមហិមាស្ទុះមកម្នីម្នាក្រាបថ្វាយបង្គំកុមារតូចទាំងពីរ ហើយប្រាប់ពួក
ស្រីស្នំដែលកំពុងអង្គុយគាល់, ប្រើអាមាត្យឲ្យហៅពួកកុង្សីយ៍សេនាបតី
នាម៉ឺនមុខមន្ត្រីព្រាហ្មណ៍ព្រឹទ្ធបុរោហិតបណ្ឌិតករ ឲ្យចូលមកខាងក្នុងបុរី
យ៉ាងឆាប់រ័រ, លុះពួករាជសេវកាមាត្យមកជួបជុំគ្នាសព្វគ្រប់ហើយ យក្ស
ស្រែកប្រកាសថា “ អ្នកពលគ្នាចូរក្រាបថ្វាយបង្គំស្ដេចមនុស្សទាំងពីរនេះ
ហើយត្រូវគោរពកោតខ្លាចយកចិត្តទុកដាក់ឲ្យដូចជាខ្លួនអញ, ដ្បិតអញ
ប្រគល់រាជ្យឲ្យស្ដេចមនុស្សលោកនេះសោយហើយ, អញសូមរួចតែខ្លួន
ប៉ុណ្ណោះទេ, ឯអ្នកទាំងអស់នៅជកក្រោមម្លប់បុណ្យស្ដេចមនុស្សលោក
នេះចុះ ” ។ ពួករាជសេវកាមាត្យទាំងអស់ក៏ក្រាបថ្វាយបង្គំកុមារទាំងពីរ
គ្រប់ៗគ្នា ឥតមាននរណាមួយហ៊ាននិយាយថាដូចម្ដេចឡើយ ។

យក្សក៏បានរៀបពិធីអភិសេកជាឯកមង្គលប្រជុំពួកពលសកលយោធាជាអនេកប្រការ ហើយប្រគល់ធីតារបស់ខ្លួនឲ្យជាមហេសី ។ ប៉ុន្តែកុមារប្អូនមិនសោយរាជ្យខ្លួនឯងទេ ឲ្យបងសោយរាជ្យវិញ ព្រោះយល់ឃើញថាបងបានចិញ្ចឹមបីបាច់ថែរក្សាខ្លួន ។ កុមារទាំងពីរសឹងនៅជាសុខសប្បាយក្នុងនគរយក្សនោះរហូតអវសានកាលទៅហោង ។

**ចប់រឿងក្មេងកំព្រាពីរនាក់តែប៉ុណ្ណោះ**

---

សុភាសិត

បើធ្វើអ្វីតែគ្មានគំនិតពិនិត្យ
ផលល្អពិតឥតអំណោយឲ្យដល់ប្រាណ,
បើធ្វើការចិត្តគិតគ្នាទាំងចំណាន
ផលតែងប្រាននឲ្យបានផលសកលសុខ ។
អ្នកធំពិតប៉ុន្តែចិត្តឥតមេត្តា
ប្រមាថអ្នកតូចទាបឲ្យទល់ទុក្ខ
គង់មានថ្ងៃអស់ព្រោះគជ័យបរាមុខ
ទោសតាមលុកឲ្យលិចលង់អន្តរាយខ្ទេច ។

យូរ-អ៊ុន

## ពុទ្ធសាសនា និង ពាហិរសាសនា

## លោក ម៉ិញ ឆា់គ្រី តំណាងរាស្ត្រ រៀបរៀង

(តមក)

---

### ២ – ព្រហ្មញ្ញសាសនា

ព្រហ្មញ្ញសាសនា ជាសាសនាកើតក្នុងកាលបរមបុរាណយូរអង្វែង លើសលែងសាសនាទាំងអស់ក្នុងលោក ចាប់កំណើតឡើងក្នុងមជ្ឈិម-ប្រទេស (ឥណ្ឌា) ឯណោះ ទើបផ្សាយរាយមកដល់ប្រទេសយើងជាខាងក្រោយ តែផ្សាយមកដល់មុនពុទ្ធសាសនា គឺសាសនាព្រាហ្មណ៍ទី ១ ពុទ្ធសាសនាទី ២ ។

សាសនានេះដែលបាននាមដូច្នេះសំគាល់សេចក្ដីថា " សាសនារបស់ព្រះព្រហ្ម " ឬ " សាសនាតមកអំពីព្រះព្រហ្ម ", ពួកព្រាហ្មណ៍ដែលប្រកាន់ខ្លួនថាជាបុត្រព្រះព្រហ្ម កាន់កាប់ប្រតិបត្តិសាសនានេះ ទើបគេហៅថា សាសនាព្រាហ្មណ៍ ។

ពួកអ្នកកាន់សាសនាព្រាហ្មណ៍ តែងគោរពរាប់អានបូជាពួកទេពតាដែលមានបណ្ដាស័ក្តិច្រើនអង្គ គឺ ព្រះព្រហ្ម, ព្រះសិវៈ (ឥស្វរ), ព្រះវិស្ណុ (នារាយណ៍), ព្រះឥន្ទ, ព្រះអាទិត្យ, ព្រះចន្ទ, ព្រះអគ្គី,

ព្រះវរុណ, ព្រះវាយុ (វាយុ), ព្រះកុវេរ, ព្រះយម, ព្រះស្កន្ទ, ព្រះកាម . . . (១) ។

ព្រះជាម្ចាស់ឬទេវតា ដែលពួកព្រាហ្មណ៍តែងគោរពបូជានោះ មានច្រើនដូច្នេះក៏ពិតមែន តែដែលធំជាងគេនោះមាន ៣ គឺ ៖ ព្រះព្រហ្ម, ព្រះសិវៈ និង ព្រះវិស្ណុ ។

## ព្រះព្រហ្ម

ព្រះព្រហ្ម សំដៅយកមហាព្រហ្ម មានជាយានាមនាង សរស្វតី មានឱរសធីតា ៣ អង្គគឺ ព្រះទក្ស ១ ព្រះកឬគុ ១ នាងសុន្ទយា ១ ។

លក្ខណៈរបស់ព្រះព្រហ្ម គឺមានព្រះកាយសម្បុរក្រហម, ទ្រង់ព្រះពស្ត្រស, មានព្រះភក្ត្រ ៤, ព្រះហស្តកាន់ផ្កាឈូក, គង់លើហង្ស ជាពាហនៈ, ទ្រង់មានញាណពិសេស អាចជ្រាបហេតុក្នុងកាលទាំងបី,

---

១ — ពួកទេវតាទាំងអស់នេះ សឹងទ្រទ្រង់នូវគុណសម្បត្តិនិងមានមុខក្រសួងផ្សេងៗគ្នា គឺ ព្រះព្រហ្មជាអ្នកបង្កើតលោក, ព្រះសិវៈ ជាអ្នកបង្កើតលោកផងបំផ្លាញលោកផង, ព្រះវិស្ណុ ជាអ្នករក្សាលោក,ព្រះឥន្ទ្រជាម្ចាស់នៃខ្យល់ព្យុះ, ព្រះអាទិត្យជាម្ចាស់ពន្លឺ ក្តៅ, ព្រះចន្ទ្រ ជាម្ចាស់ពន្លឺ ត្រជាក់, ព្រះអគ្គីជាមេភ្លើង, ព្រះវរុណជាមេភ្លៀង, ព្រះវាយុជាមេខ្យល់, ព្រះកុវេរ ជាម្ចាស់សម្បត្តិ, ព្រះយមជាស្តេចសេចក្តីស្លាប់, ព្រះស្កន្ទជាស្តេចសឹក, ព្រះកាមជាស្តេចសេចក្តីស្នេហា ។ ពួកទេវតាទាំងនេះលើកលែងតែព្រះវិស្ណុ, ព្រះអគ្គី, ព្រះវាយុ និងព្រះកាម ៤ អង្គនេះចេញ ក្រៅពីនេះហៅថា គណទេព (ទេពជំនុំ) ព្រោះតែងចូលកាន់ទេវសន្និបាតជាប្រក្រតី ដើម្បីពិភាក្សាគ្នាអំពាំហេតុភេទផ្សេងៗ ។ ពួកទេវតាដែលពួកព្រាហ្មណ៍តែងនិយមរាប់អានមិនអស់ហើយត្រឹមប៉ុណ្ណោះទេ នៅមានច្រើនតទៅទៀត ។

មានអានុភាពស័ក្តិសិទ្ធិ   អាចបំពេញចិត្តនៃអ្នកប្រព្រឹត្តតាមឲ្យសំរេចប្រយោជន៍តាមត្រូវការ ។

ព្រះព្រហ្មជាបិតារបស់លោក (ជាជនកររបស់លោក) ព្រោះគម្ពីរព្រាហ្មបុរាណ៍មសំដែងថា "មុនដែលទឹងកើតលោក ព្រះព្រហ្មជប់ឲ្យកើតពងមួយសិន ហៅថា "ពងព្រះព្រហ្ម" រួចហើយទ្រង់បែងភាគឲ្យកើតជាមនុស្ស ២ នាក់គឺ ប្រុស ១ ស្រី ១, ប្រុសហៅថាបុម, ស្រីហៅថាវិរជ្ជា, គូស្វាមីភរិយាទាំងនេះបានរួមរសប្រវេណីជាមួយគ្នា កើតជាពូជធារពាសពេញសកលលោក" ។ ហេតុនោះបានជាពួកព្រាហ្មណ៍ប្រកាន់ពួកខ្លួនថាជាវង្សខ្ពស់បំផុត ព្រោះជាវង្សរបស់ព្រះព្រហ្ម ។

## ព្រះសិវៈ

ព្រះសិវៈ ប្រែថា "ករុណា, ក្សេមបាកទុក្ខភ័យ" កើតឡើងអំពីតំណក់លោហិតដែលស្រក់ចុះពាកចិញ្ចើមរបស់ព្រះព្រហ្ម, មានព្រះជាយានាមឧមាភគវតី, មានឱរស ២ អង្គគឺ ព្រះវិឃនេស និងព្រះកត្តិកេយ (ស្កន្ទកុមារ), មានគោឧសភឈ្មោះ នន្ទិយ ជាពាហនៈ ។ លក្ខណៈរបស់ព្រះអង្គគឺមានព្រះកាយសម្បុរស, ព្រះសុរង្គសម្បុរខៀវ, ទ្រង់ស្បែកខ្លាឃ្មុំ ជាព្រះពស្ត្រ, មានព្រះមោលីសម្បុរលឿងក្តួចផ្គុំគ្នាលើព្រះសិរ, មានព្រះនេត្របីគឺពីរដូចមនុស្សធម្មតា មួយទៀតចំកណ្តាលព្រះនលាដៈ (ថ្ងាស),

មានពុកចង្កាវែងបែបព្រាហ្មណ៍, មាននាគជាសង្វារ (ជាគ្រឿងកប់ឆ្នាំ), មានពិណព្រះចន្ទចាំងរស្មីព្រាកៗ (ជាគ្រឿងសំគាល់កប់ខែ), មានឆ្អឹងលលាដ៍ក្បាល.. (ជាគ្រឿងសំគាល់កល្បយុគ), ទ្រង់អាវុធឈ្មោះចក្រ-ករី នឹងគទា (ដំបង) ព្រះខាន់ឬសារ ត្រីសូល៍, មានភេរីឈ្មោះឌុមរូ; ទ្រង់ស្ទាត់ជំនាញខាងសិល្បសាស្ត្រ នឹង នាដសាស្ត្រ, ជាមហាយោគី ទ្រទ្រង់នូវអានុភាពនឹងព្រះគុណ, ឋិតនៅក្នុងវិមានលើកំពូលភ្នំកៃលាស ។ ព្រះសិវៈជាបិតារបស់លោក ជាអ្នកកសាងលោក, ព្រោះមានសេចក្ដីក្នុងគម្ពីរព្រាហ្មណ៍ ឈ្មោះសិវបុរណម៍ នឹងឈ្មោះកថាសរិតសាគរ សំដែងថា: "ទ្រង់វះសាច់ភ្លៅឲ្យឈាមមួយដំណក់ស្រក់ចុះទៅក្នុងទឹក កើតឡើងជាពងមួយ ហើយបែកទៅជាពីរចំហៀង, មួយចំហៀងកើតជាសួគ៌លោក មួយចំហៀងទៀតកើតជាមនុស្សលោក ទើបកើតជាបុម (បុរស). បុមនោះបង្កើតជាប្រជាបតីៗបង្កើតមនុស្សតៗមក" ។

អាស្រ័យជំនឿថា ព្រះសិវៈជាបិតាលោក ទើបព្រាហ្មណ៍និកាយប្រតិតសាងអនុស្សាវរីយទុកជាទីរលឹក គឺធ្វើរូបសិវលិង្គ (លិង្គព្រះឥសូរ) នឹងរូបឧមាយោនី (យោនីនាងឧមា) ទុកសម្រាប់ធ្វើពិធីសិវរាត្រី លាងបាប លាងចង្រៃឧបទ្រពទាំងពួង ។

# ព្រះវិស្ណុ

ព្រះវិស្ណុ ឬ ព្រះនារាយណ៍ មានលក្ខណៈរូបឆោមសម្បុរខ្មៅ, ព្រះហស្តប្រក្រតីតែពីរ តែអាចបែងចេញទៅជា ៤ ឬ ៨ ក៏បាន, ព្រះឧរមានលាយល័ក្ខណ៍ធ្វតៗ ហៅថាស្រីវ័ត្ស, ទ្រង់អាភរណៈទិព្វពណ៌លឿង, ទ្រង់ស័ង្ខឈ្មោះបញ្ចជន្យជាអាវុធ, ចក្រឈ្មោះសុទស្សនៈ, គទាឈ្មោះកោមោទកី, ធនូឈ្មោះសារង្គ, ព្រះសែងខាន់ឈ្មោះនន្ទក, កាន់ផ្កាឈូកជាគ្រឿងសំគាល់. មានគ្រុឌកជបក្សីជាពាហនៈ, ព្រះជាយានាមលក្ស្មី, មានឧរសឈ្មោះកាមទេព, ទីដែលស្ថិតនៅឈ្មោះវៃកុណ្ឋ ។

ព្រះទាំង ៣ អង្គនេះ មានគុណសម្បត្តិផ្សេងៗគ្នា គឺ ព្រះព្រហ្មជាអ្នកសាងលោក, ព្រះឥសូរជាអ្នកសាងលោកផង បំផ្លាញលោកផង, ព្រះវិស្ណុជាអ្នកជួយស្រោចស្រង់លោក ទើបមាននាមថា ហរិ “ករុណានារាយណ៍” “ជាដែនកើតនៃនរជន” ។

# គម្ពីរត្រៃវេទ

ព្រាហ្មណសាសនិកជន រមែងគោរពបូជាទេពតាដូចបានពោលមក ហើយ និង ប្រតិបត្តិតាមគម្ពីរត្រៃវេទនិងវេទាង្គជាគម្ពីរធំ ។

ឯគម្ពីរត្រៃវេទនោះមាន ៣ គឺ:

១ — គម្ពីរសាមវេទ សំដែងអំពីពិធីអារក្ខពលីកម្ម បួងសួងសូមឲ្យព្រះឥន្ទ្រនឹងព្រះពរុណជួយអភិបាលមនុស្សលោក ឲ្យមានភ្លៀងធ្លាក់ត្រូវតាមរដូវកាល ។

២ — គម្ពីរអេសូវេទ ឬ គរុវេទ សំដែងអំពីពិធីគុស្ដិ, សូមឲ្យព្រះវិស្សុកម្ម ព្រះមារុត ព្រះព្រហ្ម ប្រទានពរឲ្យសំរេចកិច្ចខាងការបាត្តកម្ម ពាណិជ្ជកម្ម នឹងលាភសក្ការៈផ្សេងៗ តាមត្រូវការ ។

៣ — គម្ពីរយជុវេទ សំដែងអំពីពិធីយុទ្ធពលីកម្មដល់ព្រះឥសូរ, ព្រះនារាយណ៍, ព្រះអាទិត្យ, ព្រះអគ្គី, សូមឲ្យមានរិទ្ធិតេជះ ជោគជ័យ ។

បណ្ដាវេទទាំង ៣ នេះ មួយៗចែកជាពីរផ្នែកគឺ វេទឬព្រហ្ម ១ ផ្នែក, មន្ត ១ ផ្នែក ។ វេទ និយាយអំពីរបៀបធ្វើពលីកម្ម, មន្ត បានដល់ពាក្យស្លោក (គាថា) សម្រាប់សូត្របួងសួងបន់ស្រន់ នឹង សរសើរព្រះជាម្ចាស់ ។

ព្រាហ្មណ៍ដែលកំពុងសិក្សាត្រៃវេទនេះ ហៅថា ព្រហ្មចារី "អ្នកប្រព្រឹត្តព្រហ្ម គឺ វេទ", អ្នករៀនចេះចប់ហើយហៅថា វេទគូ "អ្នកដល់នូវទីបំផុតនៃវេទ" ឬ បារគូ "អ្នកដល់នូវត្រើយនៃវេទ" ។ ហេតុនោះ ព្រាហ្មណ៍ទើបមាន ២ ពួក គឺ ព្រាហ្មណ៍ដោយជាតិ ១ ព្រាហ្មណ៍ដោយគុណធម៌ ១ ។

# សេចក្តីបដិបត្តិក្នុងលទ្ធិព្រាហ្មណ៍

អ្នកកាន់លទ្ធិនេះយល់ថា លោកធាតុនិងវត្ថុធាតុ ធម្មជាតិទាំងអស់ក្នុងពិភពលោកនេះ សុទ្ធតែព្រះទ្រង់សាងឡើង ហើយសុទ្ធតែមានទេវតាប្រចាំ សុទ្ធតែមានទេវតាជាម្ចាស់; ហេតុនេះ ត្រូវតែប្រតិបត្តិខ្លួនឲ្យត្រូវព្រះទ័យព្រះជាម្ចាស់និងពួកទេវតា ទើបមានសេចក្តីសុខចំរើន ។

ឯកិច្ចដែលត្រូវប្រតិបត្តិនោះ មាន ៣ យ៉ាង គឺ:

១ – កិច្ចបំពេញតប:

២ – ពិធីបូជាព្រះអគ្និ ឬ បូជាយញ្ញ

៣– ពិធីសិរីកក្រិត ( លាងបាប ) ។

**កិច្ចបំពេញតប:** គឺទរមានរាងកាយឲ្យលំបាកដោយកិច្ចវត្តផ្សេងៗ មានប្រព្រឹត្តវត្តឈរជាដើម ឲ្យទាល់តែលំបាកទៀបស្លាប់ឬស្លាប់ទៅក៏មាន ដើម្បីឲ្យក្តៅរំជួលដល់ព្រះជាម្ចាស់ ហើយទ្រង់ប្រសិទ្ធិប្រទានពរឲ្យតាមប្រាថ្នា ។

**ពិធីបូជាព្រះអគ្និ** នោះចែកចេញជា ៤ គឺ បង្រៀនវេទដល់សិស្សគណ ហៅថា បូជាវេទ ១, សែនព្រេនដោយគ្រឿងសំណែនមាននំជាដើម ហៅថា បូជា . . . ១, ដុតរបស់ក្នុងភ្លើងថ្វាយទេវតា ហៅថា បូជា . . . ១, ឲ្យអាហារជាទាន ហៅថា បូជាសត្វ ១ ។:

**ពិធីសិវរាត្រី** សម្រាប់ប្រទេសឥណ្ឌា គេធ្វើក្នុងទន្លេគង្គា ដោយគេយល់ថា ជាមេទឹកស័ក្តិសិទ្ធិដែលហូរចុះពីឋានសួគ៌ សម្រាប់លាងជំរះបាបរបស់សត្វ ។

ពិធីនេះ ពួកព្រាហ្មណ៍ស្រុកពារាណសី វេលាយប់នាំគ្នាទៅវត្តព្រាហ្មណ៍ ដែលជាទេវឋាន ធ្វើកិច្ចសូត្រមន្ត បំរើនភាវនា នមស្សការទេវរូបទីងសិវលិង្គ តាមប្រវេណីរហូតអស់រាត្រី. ទៀបភ្លឺ ទើបនាំគ្នាយកក្អមស្ពាន់មួយៗម្នាក់ទៅកាន់ស្ទឹងគង្គា អង្គុយដងយកមកស្ងូតសេក ខ្ពុរមាត់លុបលាងខ្លួនប្រាណ ហើយចុះងូតមុជឲ្យលិចក្បាលអស់វារៈ ៣ ដង ហើយមុជទ្វេះយកដីមកដុះខ្លួនប្រាណ ទីង ធ្វើបរិកម្មថា "គង្គា! គង្គា!" កិច្ចប៉ុណ្ណោះ ឈ្មោះថាបានជំរះលាងបាបអស់អំពីខ្លួនសន្ដាន រួចហើយទើបដងទឹកយកមកកាន់ទេវឋានវិញ ដល់ហើយយកទឹកនោះទៅស្រោចស្រប់សិវលិង្គ ទើបត្រងទឹកដែលហូរចុះតាមទវារនៃបល្ល័ង្កឧមាយោនី យកមកស្រោចក្បាល ស្រលាបខ្លួនប្រាណ ផឹកតាមសេចក្ដីត្រូវការ ឈ្មោះថាបានសិរីសួស្ដីជ្រះអស់ចង្រៃឧបទ្រពទាំងពួង ។

ឯកំពង់សម្រាប់ចុះងូតនោះ តាមដែលគេសម្គាល់ទុកមាន ៣ អន្លើគឺ កំពង់ព្រះព្រហ្ម ១ កំពង់ព្រះវិស្ណុ ១ កំពង់ព្រះឥសូរ ១ ៗ កំពង់ទាំង ៣ នេះ មានគុណផ្សេងៗគ្នា ស្រេចហើយតែអ្នកត្រូវការចង់ចុះងូតកំពង់

ណាក៏បាន ។ ត្រង់ផ្លោយស្រុកអលូហាបាទ មានកំពង់មួយស័ក្តិសិទ្ធ ជាងគេ ហៅថា " ប្រយាគ " មានប្រជុំជននិយមចុះងូតកប់ទាំងសែន ។

សម្រាប់ស្រុកភូមិដែលនៅឆ្ងាយអំពីទន្លេគង្គា, បើអ្នកណាបានទៅងូតម្តងៗ តែងជងយកទឹកនោះមកផ្ញើញាតិមិត្ត ឲ្យលុបលាងមុខមាត់ស្រលាបខ្លួនប្រាណ ហើយបរិកម្មថា " គង្គា! គង្គា! ", សូម្បីនៅចម្ងាយ ៣០ យោជន៍ ក៏គង់រួចបាបបាបដែលខ្លួនបានធ្វើមក ៣ ជាតិហើយ ។

ហេតុនេះ ទើបបានជាពួកឥណ្ឌា ដែលមានសទ្ធាជ្រះថ្លាខ្លាំង វេលាទៀបស្លាប់ឲ្យបាន់ទៅស្លាប់ក្បែរទន្លេគង្គា ស្លាប់ហើយឲ្យគេដុតយកធាតុទៅគ្រវែងបាចសាចបោលក្នុងទន្លេនោះ ឈ្មោះថាបានជ្រះបាបគគ សេសសល់ ។

សម្រាប់ប្រទេសឆ្ងាយៗ ក្រៅពីប្រទេសឥណ្ឌា, ពិធីសិវរាត្រីនេះ គេយកសិវលិង្គទៅដំកល់ទុកក្នុងទីណាមួយ ហើយដាំសសរ ៤ ជុំវិញសិវលិង្គ រួចយកខ្សែចងខ្វែងសសរទាំងនោះ ទើបយកក្អមឬឆ្នាំងចោះធម្មះហើយយកមកព្យួរនឹងខ្សែនោះឬចងនឹងមែកឈើក៏បាន ហើយចាក់ទឹកក្នុងឆ្នាំងនោះ ឲ្យស្រក់ចុះមកចំលើលិង្គនោះ ដើម្បីឲ្យហូរទៅតាមបល្ល័ង្កឧមាយោនី ជាបដល់អស់រាត្រីកាល, ដល់វេលាទៀបភ្លឺគេនាំគ្នាជណ្តាំបាយ លាយដោយទឹកដោះ ទឹកឃ្មុំ ស្ករនឹងគ្រឿងទេសផ្សេងៗ ដែលចាត់ថាជាបណ្ណាការ នាំគ្នាបរិភោគ ហើយទៅងូតទឹកទន្លេឬព្រែកជំនួស

ទន្ទេគង្គា រួចហើយទើបយកទឹកសិវលិង្គ ស្រោចស្រប់ខ្លួនប្រាណថែមទៀត កិច្ចប៉ុណ្ណោះឈ្មោះថាស្រោចកិច្ចសិវរាត្រី ។

ពិធីនេះ គេធ្វើក្នុង ១ ឆ្នាំតែម្តង ហើយបានតែក្នុងវេលាពេលរាត្រីផង ទើបហៅថា ពិធីសិវរាត្រី ។

## ផលនៃការប្រតិបត្តិក្នុងលទ្ធិព្រាហ្មណ៍

និកាយព្រាហ្មណ៍គោរពពប់អាន ព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ នឹង ប្រព្រឹត្តតាមពាក្យប្រដៅក្នុងគម្ពីរត្រៃវេទ ។ ផលប្រយោជន៍ក្នុងការប្រតិបត្តិមាន ២ យ៉ាងគឺ ១ – ប្រយោជន៍ក្នុងលោកនេះ, ២ – ប្រយោជន៍ក្នុងលោកខាងមុខ ។ ប្រយោជន៍ទី ១ សម្រាប់ពួកគ្រហស្ថ, ប្រយោជន៍ទី ២ សម្រាប់ពួកបព្វជិតដែលនៀយណាយកុងយកកសកិច្ច ហើយចេញទៅបួសជាតាបស - ឫសី ស្ងឹងស្ងាធ៍ប្រព្រឹត្តតបៈផ្សេងៗ ក្នុងព្រៃភ្នំក្រិច មានផ្លែឈើមើមឈើជាអាហារ ដើម្បីឲ្យបានលុះគុណវិសេសជាន់ខ្ពស់ ។

បព្វជិតដែលប្រព្រឹត្តតឹងរឹងដល់កំរិតដល់ថ្នាក់ ចាត់ថាជាអ្នកបានលុះគុណវិសេសនោះៗហើយ បែកជា ៤ ពួកគឺៈ ១ – រាជឫសី, ២ – មុនី, ៣ – មហាឫសី, ៤ – ព្រហ្មឫសី ។

សរុបសេចក្ដីៈ ឫសីទាំង ៤ នេះ សឹងនៅប្រកបដោយរាគាទិក្កិលេសនៅឡើយ ព្រោះមានរឿងដំណាលថា ឫសីខ្លះមានប្រពន្ធកូន, ខ្លះញុះញង់សម្លាប់គេជាដើម កុំថាឡើយតែពួកព្រហ្មបរិសុទ្ធដែលទំ

ប្រតិបត្តិដល់ថ្នាក់ត្រឹមប៉ុស្មប៉ុណ្ណោះ សូម្បីព្រះព្រហ្ម ព្រះសិវៈ ព្រះវិស្ណុ ដែលគេប្រកាន់ថាជាព្រះមេលទ្ធិសាសនា ក៏សុទ្ធតែនៅមានប្រពន្ធកូន មានកំហឹង មានសេចក្ដីព្យាបាទបៀតបៀនអ្នកដទៃនៅឡើយ, បើតាមសេចក្ដីសង្កេតទៅឃើញថា ពួកទេពតាទាំងប៉ុស្មទាំងនោះនៅមានរាគៈ ទោសៈ មោហៈ ដូចបុថុជ្ជនធម្មតា ។

---

## លទ្ធិគ្រូ ៦

ក្នុងសម័យពុទ្ធកាល ពាហិរសាសនាក្រៅអំពីសាសនាព្រាហ្មណ៍ នៅមានលទ្ធិដទៃៗទៀត ដែលជាលទ្ធិឆ្ងុយទាស់នឹងព្រះពុទ្ធសាសនា គឺលទ្ធិគ្រូ ៦ ។

ឯឈ្មោះគ្រូទាំង ៦ នោះ គឺបូរណកស្សប ១ មក្ខលិគោសាល ១ និគណ្ឋនាដបុត្ត ១ សញ្ជយវេលដ្ឋបុត្ត ១ បកុទ្ធកច្ចាយន ១ អជិតកេសកម្ពល ១ ។

## ប្រវត្តិរបស់គ្រូទាំង ៦ (សង្ខេប)

១ – **បូរណកស្សប** គ្រូនេះមានសេចក្ដីដំណាលថា: មានត្រកូលអ្នកមានម្នាក់ មានខ្ញុំប្រុស-ស្រីចំនួន៩៩នាក់, ក្នុងចំណោមខ្ញុំទាំងនេះ មានខ្ញុំម្នាក់មានកូនប្រុសមួយទើបនឹងកើតមក រួមទាំងខ្ញុំមុនផងត្រូវជា ១០០ ទើបគេកំណត់ឲ្យឈ្មោះទារកក្រោយនេះថា បូរណៈ ប្រែថា "បំពេញ" ព្រោះបង្គ្រប់ជា ១០០ នឹងខ្ញុំមុន ចាត់ថាជាខ្ញុំមង្គល ។

អាស្រ័យហេតុនេះ ទោះបីទារកនោះ ធ្វើកិច្ចការអ្វីល្អក្តីអាក្រក់ក្តី ឬធ្វើក្តី មិនធ្វើក្តី ក៏ទៅហួយនាយ មិនដែលស្តីបន្ទោសសោះឡើយ ។

ថ្ងៃមួយ ខ្ញុំប្រុសនោះគិតឃើញថា " ការដែលនៅទទេៗដូច្នេះមិនមានប្រយោជន៍អ្វីឡើយ ", ទើបវាត់ចេញចាកទីនោះទៅ, លុះវាត់ទៅដល់ប្រទេះទឹងចោរ ៗ ដណ្តើមយកសំពត់សម្លៀកបំពាក់អស់រលីង រកអ្វីស្លៀកមិនបាន ក៏ចូលទៅកាន់ភូមិមួយទាំងខ្លួនអាក្រាតទទេ ។ ពួកមនុស្សអ្នកស្រុកឃើញដូច្នោះ ក៏យល់ឃើញថាជាសមណៈអរហន្ត អ្នកមានសេចក្តីប្រាថ្នាតិច រកបុគ្គលដទៃស្មើគ្មាន, ហើយនាំគ្នាបូជាដោយនំចំណីផ្សេងៗ។ បុរសអាក្រាតនោះឯង អាស្រ័យរឿងនេះ ទើបកើតគំនិតថ្មីឡើងថា " លាភសក្ការៈទេយ្យវត្ថុទាំងនេះដែលកើតឡើងដល់អញ ព្រោះអាស្រ័យការអាក្រាតកាយ បើដូច្នោះមិនត្រូវស្លៀកសំពត់ទេ " ម៉្លោះហើយចាប់ដើមតាំងអំពីកាលនោះមក ទោះបីមានសំពត់ក៏មិនស្លៀកដណ្តប់ឡើយ ហើយប្រកាន់យកការអាក្រាតកាយនោះថាជាកិច្ចបព្វជ្ជា ជាភេទរបស់អ្នកបួស, តមកទើបមានមនុស្សជាច្រើនរយចូលបួសក្នុងសំណាក់គ្រូនោះ ។

លទ្ធិរបស់គ្រូនេះ ជាអកិរិយវាទ ( ប្រកាន់ថាមិនមានអំពើ ) គឺប្រកាន់ថាបុគ្គលដែលធ្វើអំពើបាបផ្សេង ៗ មានការសម្លាប់សត្វ លួចទ្រព្យអ្នកដទៃ ធ្វើបរទារកម្ម និយាយមុសាវាទជាដើម មិនឈ្មោះថា

ធ្វើអំពើបាបទេ មិនមានបាបទេ ឥតមានទោសឡើយ ។ ហេតុនោះគ្រូនេះឈ្មោះថា អកិរិយវាទី “អ្នកពោលប្រកាន់ថាមិនមានអំពើ” ។

២ — មក្ខលិគោសាល គ្រូនេះមានរឿងដំណាលថា គាត់កើតក្នុងរោងគោជាទាសៈរបស់ជនម្នាក់ ។ លុះធំឡើង ចៅហ្វាយបានប្រើឲ្យកាន់ឆ្នាំងខ្លាញ់ដើរកណ្ដាលភ្លៀង ប្រកបដោយដីរអិលប៉ិចប៉ុច ហើយហាមប្រាម (តាមភាសាបាលី) ថា: មា ខលិ “ប្រយ័ត្នរអិល” ថាមិនទាន់ផុតមាត់រអិលដួលព្រុះ, ដោយសារសេចក្ដីខ្លាចម្ចាស់ គាត់ក៏រត់ទៅបណ្ដោយ, ចៅហ្វាយក៏ដេញតាមចាប់ជាយសំពត់ជាប់ គាត់ប្រឹងបំរះរបូតទៅ សល់នៅតែកាយទទេហើយរត់បាត់ទៅ ។

ពួកមនុស្សដែលឆោតល្ងង់ខ្លៅ ឃើញដូច្នោះក៏សំគាល់ថាជាព្រះអរហន្ត មានសេចក្ដីប្រាថ្នាតិច, ហើយនាំគ្នាគោរពបូជា ។ បុរសនោះអាស្រ័យលាភសក្ការៈក៏ឡើងជោរ សំគាល់ខ្លួនថាជាព្រះអរហន្តមែន ហើយប្រព្រឹត្តវត្តអាក្រាតកាយនោះតមក ។

ឯលទ្ធិរបស់គ្រូនេះ ជាអហេតុកទិដ្ឋិ (ប្រកាន់ថាមិនមានហេតុបច្ច័យ) គឺប្រកាន់ថា: នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ សង្កិលេសាយ មិនមានហេតុមិនមានបច្ច័យដើម្បីញ៉ាំងសត្វឲ្យសៅហ្មង, អហេតូ អប្បច្ចយា សត្តា សង្កិលិស្សន្តិ សត្វទាំងឡាយមិនមានហេតុមិនមានបច្ច័យ នាំឲ្យសៅហ្មងទេ. នត្ថិ ហេតុ នត្ថិ បច្ចយោ

សត្តានំ វិសុទ្ធិយា មិនមានហេតុ មិនមានបច្ច័យ ញ៉ាំងសត្វទាំងឡាយឲ្យបរិសុទ្ធ, អហេតូ អប្បច្ចយា សត្តា វិសុជ្ឈន្តិ សត្វទាំងឡាយមិនមានហេតុ មិនមានបច្ច័យនាំឲ្យបរិសុទ្ធ (សត្វដែលនឹងសៅហ្មងក៏សៅហ្មងឯង, នឹងបរិសុទ្ធក៏បរិសុទ្ធឯង) ។ ហេតុនោះគ្រូនេះទើបឈ្មោះថា ជាអហេតុកវាទី "អ្នកពោលប្រកាន់ថាមិនមានហេតុ" ។

៣— **និគណ្ឋនាដបុត្ត** (គ្រូនេះមានរឿងដំណាលថា: គាត់ជាកូនរបស់អ្នករបាំ (នាដបុត្ត) មានសេចក្តីប្រកាន់មានដើមថា: អម្ហាកំ គណ្ឋនត្ថិ កិលេសោ នត្ថិ យើងមិនមានកិលេសជាគ្រឿងចាក់ស្រែះរិតរួតទេ, កិលេសគណ្ឋរហិតា យើងប្រាសចាកគ្រឿងចាក់ស្រែះរិតរួតគឺកិលេសហើយ ។

ម្យ៉ាងទៀត លទ្ធិរបស់គ្រូនេះ ប្រកាន់យកការសង្រួមទាំង ៤ គឺ: សព្វវារិវារិតោ ឃាត់ហាមទឹកទាំងពួង ១ សព្វវារិយុត្តោ ប្រកបដោយទឹកទាំងពួង ១ សព្វវារិធុតោ កំចាត់បាបដោយទឹកទាំងពួង ១ សព្វវារិផុដោ ប្រោះព្រំដោយទឹកទាំងពួង១, បុគ្គលដែលប្រកបដោយការសង្រួមទាំង ៤ យ៉ាងនេះឈ្មោះថា ជាអ្នកដល់នូវទីបំផុត ជាអ្នកសង្រួម ជាអ្នករក្សាខ្លួនបានល្អ ។

គ្រូនេះជា និគណ្ឋវាទី អ្នកប្រកាន់ថាខ្លួនមិនមានកិលេស មិនមានគ្រឿងសៅហ្មង ។

៤ — សញ្ជ័យ គ្រូនេះមានសេចក្ដីថា: គាត់ជាកូនអ្នកត្បាញផែង (វេលដ្ឋបុត្ត) ទើបគេហៅថា សញ្ជ័យវេលដ្ឋបុត្ត ។

ឯលទ្ធិរបស់គ្រូនេះ ប្រកាន់អមរាវិក្ខេបទិដ្ឋិ គឺសេចក្ដីយល់ប្រកបដោយវាចាមិនស្ទាប់, ឬសេចក្ដីយល់បម្រះដូចជាអន្ទង់, សេចក្ដីយល់ចាក់បណ្ដោយ, និយាយដោះខ្លួនឲ្យតែរួចមិនឲ្យគេចាប់ថ្នាក់បាន ។ បើមានគេសួរថា លោកខាងមុខមានឬមិនមាន? ពួកសត្វជាឧបបាតិកមានឬមិនមាន? ផលវិបាកនៃកម្មល្អនិងកម្មអាក្រក់មានឬមិនមាន? ។ គាត់ឆ្លើយថា បើសេចក្ដីយល់របស់ខ្ញុំថាមាន ខ្ញុំឆ្លើយថាមាន, បើមិនមាន—ថាមិនមាន, បើមានខ្លះ មិនមានខ្លះ—ថាមានខ្លះមិនមានខ្លះ, បើមានក៏មិនមែនមិនមានក៏មិនមែន — ថាមានក៏មិនមែនមិនមានក៏មិនមែន, តែសេចក្ដីយល់របស់ខ្ញុំយ៉ាងនេះក៏មិនមែន យ៉ាងនោះក៏មិនមែន យ៉ាងដទៃក៏មិនមែន ថាមិនមែនក៏ទេ ថាមិនមែនទេក៏ទេដែរ ។ បើមានគេសួរថា សត្វស្លាប់ហើយកើតទៀត ឬមិនកើតទៀត? ។ គាត់ឆ្លើយថា បើសេចក្ដីយល់របស់ខ្ញុំថាកើតទៀត ខ្ញុំនឹងឆ្លើយថាកើតទៀត, បើមិនកើតទៀត - ថាមិនកើតទៀត, កើតទៀតខ្លះ មិនកើតទៀតខ្លះ - ថាកើតទៀតខ្លះមិនកើតទៀតខ្លះ, កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន - ថាកើតទៀតក៏មិនមែនមិនកើតទៀតក៏មិនមែន, តែសេចក្ដីយល់របស់ខ្ញុំយ៉ាងនេះក៏មិនមែន

យ៉ាងនោះក៏មិនមែន យ៉ាងដទៃក៏មិនមែន - ថាមិនមែនក៏ទេ ថាមិនមែនទេក៏មិនមែនដែរ ។

ទិដ្ឋិរបស់គ្រូនេះ ហៅថា អមរាវិក្ខេបទិដ្ឋិ "សេចក្ដីយល់ប្រកបដោយការចាប់មិនស្លាប់" ឬ "សេចក្ដីយល់បម្រះដូចជាអន្ទង់" ។

**៥ – បកុទ្ធកច្ចាយនៈ** គ្រូនេះមានរឿងដំណាលថា: គាត់ជាអ្នកបដិសេធមិនប្រើប្រាស់ទឹកត្រជាក់ ដោយយល់ឃើញថាមានសត្វអាស្រ័យនៅ ។ គ្រូនេះសូម្បីបន្ទោបង់នូវលាមកក្ដី បរិភោគភោជនក្ដី បង្ហាក់ដោយវត្ថុមិនស្អាតណាមួយហើយ មិនព្រមប្រើប្រាស់ធ្វើកិច្ចនោះៗ ដោយទឹកទេ កាលបើបានទឹកក្ដៅ ឬ ទឹកបាយទើបធ្វើកិច្ចទាំងនោះ ។ កាលបើដើរឆ្លងស្ទឹង ឬ ឆ្លងទឹកដែលមាននៅកណ្ដាលផ្លូវ តែងធ្វើផ្កាខ្សាច់អធិដ្ឋានសីលរួចហើយទើបដើរឆ្លងហួសទៅ ដោយយល់ឃើញថា បើមិនបានធ្វើយ៉ាងនេះនឹងដាច់សីល ។

ម្យ៉ាងទៀតគ្រូនេះយល់ថា កាយ៧យ៉ាងគឺ បឋវីកាយ (ពួកធាតុដី)១ អាបោកាយ (ពួកធាតុទឹក)១ តេជោកាយ (ពួកធាតុភ្លើង)១ វាយោកាយ (ពួកធាតុខ្យល់)១ សុខៈ (សេចក្ដីសុខ)១ ទុក្ខៈ (សេចក្ដីទុក្ខ)១ ជីវិតៈ (ជីវិត)១ គ្មាននរណាធ្វើកើតនិម្មិតបានសាងបានទេ ជាសភាវៈតាំងនៅមាំដូចជាកំពូលភ្នំ ឬ ដូចជាសសរគោល មិនចេះញាប់ញ័រប្រែប្រួល មិនចេះបៀតបៀនគ្នា មិនអាចធ្វើគ្នាឲ្យបានសុខ - ទុក្ខទេ (ហេតុនោះ)

បុគ្គលសម្លាប់ខ្លួនឯងក្តី ឲ្យគេសម្លាប់ក្តី ស្កាប់ខ្លួនឯងក្តី ប្រើគេឲ្យស្កាប់ក្តី ដឹងខ្លួនឯងក្តី ញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់ក្តី មិនមាននៅក្នុងកាយទាំងនោះឡើយ ទុកណាជាបុគ្គលនោះកាត់សីសៈដោយគ្រឿងសស្ត្រាដ៏មុត ក៏ឈ្មោះថាគ្មាននរណាសម្លាប់អ្នកណាទេ គ្រឿងសស្ត្រានោះគ្រាន់តែចូលទៅកាន់ចន្លោះកាយទាំង ៧ ប៉ុណ្ណោះឯង ។

គ្រូនេះជា អកិរិយវាទី “អ្នកប្រកាន់ថាមិនមានអំពើ” ។

៦ – **អជិតកេសកម្ពល** គ្រូនេះប្រើប្រាស់តែសំពត់កម្ពលធ្វើពីសក់មនុស្ស ប្រកាន់ឧច្ឆេទទិដ្ឋិ “សេចក្តីយល់ឃើញថាសូន្យ” គឺប្រកាន់ថា:

១ – នត្ថិ ទិន្នំ ទានដែលបុគ្គលឲ្យហើយមិនមានផល

២ – នត្ថិ យិដ្ឋំ ការបូជាធំមិនមានផល

៣ – នត្ថិ ហុតំ ការបូជាតូចមិនមានផល

៤ – នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ ផលវិបាកនៃកម្មដែលបុគ្គលធ្វើល្អនិងធ្វើអាក្រក់មិនមាន

៥ – នត្ថិ អយំ លោកោ លោកនេះមិនមាន

៦ – នត្ថិ បរោ លោកោ លោកខាងមុខមិនមាន

៧ – នត្ថិ មាតា សេចក្តីប្រតិបត្តិក្នុងមាតាមិនមានផល

៨ – នត្ថិ បិតា សេចក្តីប្រតិបត្តិក្នុងបិតាមិនមានផល

៩ — ឧត្ថិ សត្តា ឱបបាតិកា សត្វជាឧបបាតិកមិនមាន

១០ — ឧត្ថិ លោកេ សមណព្រាហ្មណា សមគ្គតា សម្មាបដិបន្នា ពួកសមណនឹងព្រាហ្មណ៍ ដែលមានសេចក្ដីព្រមព្រៀងគ្នា ប្រតិបត្តិដោយប្រពៃ ក្នុងលោក មិនមាន ។

មួយទៀត ប្រកាន់ថាបុរសដែលប្រកបដោយមហាភូតរូប ៤ បែកធ្លាយកាយទៅហើយសូន្យគឺ: ធាតុដីទៅជាដី ធាតុទឹកទៅជាទឹក ធាតុភ្លើងទៅជាភ្លើង ធាតុខ្យល់ទៅជាខ្យល់ ឥន្ទ្រិយទាំង ៦ សាត់អណ្ដែតទៅក្នុងអាកាស ឥតមានអ្វីខាងមុខអំពីសេចក្ដីស្លាប់ទៅទៀយ ។

ហេតុនោះគ្រនេះ ឈ្មោះថាជា ឧច្ឆេទទិដ្ឋិ "អ្នកប្រកាន់ថាសូន្យ" ។

(មានត)

# ខុរប្បជាតក

## ក្នុងអង្គុត្តរនិកាយ តិកនិបាត

ឃុន បណ្ណានុរក្ស ប៊ូ-ប៉ូ ពុទ្ធសាសនបណ្ឌិត្យ ប្រែរៀបរៀង

---

ទិស្វា ខុរប្បេតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ ឯកំ ឱស្សដ្ឋវីរិយំ ភិក្ខុំ អារព្ភ កថេសិ ។

សត្ថា គឺសម្តេចព្រះបរមគ្រូកាលគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកលះបង់សេចក្តីព្យាយាមមួយរូប ទើបត្រាស់សំដែងធម៌ទេសនានេះ មានបទព្រះគាថាតាំងផ្តើមទុកថា ទិស្វា ខុរប្បេ ដូច្នេះជាដើម ។

តំ ហិ សត្ថា ដំណើរសេចក្តីថា សម្តេចព្រះបរមសាស្តាត្រាស់សួរភិក្ខុនោះ ដែលភិក្ខុទាំងឡាយនាំមកកាន់រោងធម្មសភាថា "ម្នាលភិក្ខុ! បានឮថា អ្នកលះបង់បោលសេចក្តីព្យាយាមមែនឬទេ?" កាលដែលភិក្ខុនោះក្រាបទូលទទួលថាពិតមែនហើយ ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុ! អ្នកបានចូលមកបួសក្នុងសាសនាតថាគត ជាសាសនានាំឲ្យបានសម្រេចមគ្គផលពិតប្រាកដដូច្នេះ ហេតុអ្វីក៏បានជាអ្នកទំលាក់សេចក្តីព្យាយាមបោលចេញទៅវិញ, អ្នកស៊ូមិនបានខឹងបណ្ឌិតទាំងឡាយអំពីកាលមុន ព្យាយាមធ្វើកងកិច្ចមិនគួរកើតសេចក្តីឧស្សាហ៍ គេក៏នៅតែមិនលះបង់សេចក្តីព្យាយាមបោលឡើយ ។ ភិក្ខុទាំងឡាយក្រាបទូលអារាធនាសម្តេចព្រះមុនីនាថ ឲ្យទ្រង់ប្រកាសសេចក្តីនោះឲ្យច្បាស់លាស់ឡើង ។ ព្រះ

អង្គទើបទ្រង់សំដែងដំណាលហេតុខាងដើម ដែលកំប៉ាំងបាត់ស្ងាត់ទៅជាយូរអង្វែងហើយនោះ ឲ្យច្បាស់ប្រាកដដូចតទៅនេះថា :

អតីតេ ពារាណសិយំ ព្រហ្មទត្តេ រជ្ជំ ការេន្តេ ។ល។

ក្នុងកាលកន្លងទៅជាយូរអង្វែងហើយ, គ្រាដែលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី, សម័យនោះ ព្រះបរមពោធិសត្វកើតក្នុងត្រកូលនៃបុគ្គលអ្នកក្រព្រៃ លុះចំរើនវ័យធំឡើងហើយ មានបុរស ៥០០ នាក់ជាបរិវារ ជាធំជាងត្រកូលដែលក្រព្រៃទាំងឡាយ បានសំណាក់អាស្រ័យនៅក្នុងស្រុកក្បែរដងព្រៃមួយ ជាអ្នកស៊ីឈ្នួលជូនពួកអ្នកដំណើរឲ្យឆ្លងកាត់ផុតពីដងព្រៃនោះទៅ ។

អថេកទិវសំ វេលាខាងក្រោយមក ក្នុងថ្ងៃមួយ សត្ថវាហបុត្រ (កូនឈ្មួញរទេះ) នៅនគរពារាណសីម្នាក់ បានបររទេះ ៥០០ ទៅដល់ស្រុកនោះហើយ ហៅព្រះពោធិសត្វមកនិយាយថា សម្ម សម្លាញ់ អ្នកចូរទទួលយកប្រាក់មួយពាន់រៀល ហើយសូមជូនចំឡងខ្ញុំឲ្យឆ្លងកាត់ផុតអំពីដងព្រៃនេះទៅផង ។ ព្រះពោធិសត្វក៏ព្រមទទួលយកប្រាក់មួយពាន់រៀលពីដៃសត្ថវាហបុត្រ, កាលដែលលោកទទួលយកថ្លៃឈ្នួលដូច្នោះហើយ លោកក៏តាំងចិត្តលែងគិតភ័យលះកាត់សេចក្ដីអាឡោះអាល័យស្ដាយជីវិតខ្លួន ក្នុងដំណើរតាមផ្លូវប្រែកប្រជោយភ័យដ៏ពន្លឹក រួចជូនសត្ថវាហបុត្រឆ្លងកាត់ព្រៃទៅ ។

៖ ឧដ្ឋវីមច្ឆេ បញ្ចសតា ចោរា ខណៈនោះ មានចោរទាំង ៥០០ នាក់ បានធ្វើដំរីសម្រាប់លាក់ខ្លួនពួនសម្ងំនៅនាកណ្ដាលដងព្រៃ ដើម្បីស្កាត់ប្លន់ពួករទេះ ចោរទាំងនោះបានឃើញរទេះទាំង ៥០០ បរទៅ ដល់ដំរីខ្លួន ក៏នាំគ្នាស្ទុះចូលទៅប្លន់ ឯអ្នករទេះកាលក្រឡេកឃើញពួកចោរ ចូលមកប្លន់ខ្លួនដូច្នោះ ក៏តក់ស្លុតភិតភ័យ នាំគ្នាប្រះជេកក្រាបលើផ្ទៃប្រថពីទាំងអស់ នៅសល់តែព្រះពោធិសត្វជាមេធំម្នាក់ឯង លោកក្រែងស្រែកសន្ធាប់ បន្លឺសំឡេងស្នូរសីហនាទ ធ្វើអាការហាក់ដូចជាមានគ្នីគ្នាច្រើនណាស់ លោកកាន់យកគុម្ពឈើធ្វើកំឡាំងឲ្យពួកចោរភ័យខ្លាចរត់បាត់អស់ទៅវិញ ទើបជូនសត្ថវាហបុត្រឲ្យរួចផុតពីទីកន្ដារៈទៅបានដោយសេចក្ដីសុខសប្បាយគ្មានអន្ដរាយអ្វីឡើយ ។

សត្ថវាហបុត្តោ បង បំណែកខាងសត្ថវាហបុត្រ លុះបានរួចផុតពីចោរភ័យទៅហើយ ក៏ដាក់រទេះឈប់នៅដំបន់មួយ អញ្ជើញព្រះពោធិសត្វឲ្យបរិភោគភោជនាហារមានរសជាតិឆ្ងាញ់ពិសាផ្សេងៗ ហើយបរិភោគបាយព្រឹកខ្លួនឯង កាលស្រេចភត្តកិច្ចហើយក៏អង្គុយសន្ទនានិយាយជាមួយនឹងព្រះពោធិសត្វថា សម្ម ម្នាលសំឡាញ់ ក្នុងពេលដែលពួកចោរទាំង ៥០០ នាក់ សុទ្ធតែជាអ្នកកាចឃោរឃៅកាន់អាវុធគ្រប់ដៃស្ទុះចូលមកកាំហែងគម្រាមនឹងប្លន់រទេះនោះ ហេតុដូចម្ដេចបានជា

អ្នកគ្មានសេចក្ដីភិតភ័យតក់ស្លុតសោះ? ។ រួចសត្តក់ហាបុត្រសួរព្រះពោធិសត្វតទៅទៀត ដោយគាថាជាបឋមថា:

ទិស្វា ខុរប្បេ ធនុវេគនុណ្ណេ
ខគ្គេ គហីតេ តិក្ខិណេ តេលធោតេ
តស្មឹ ភយស្មឹ មរណេ វិយូឡ្ហេ
កស្មា នុ តេ នាហុ ឆម្ភិតត្តំ ។

(សេចក្ដីថា) កាលអ្នកឃើញចោរទាំងឡាយបាញ់កូនសរដ៏ស្រួចនឹងកាន់ដាវដ៏មុត ដែលដុសខាត់ហើយដោយប្រេង, កាលមរណភ័យនោះចូលមកដល់ចំពោះមុខហើយ ហេតុដូចម្ដេចបានជាអ្នកមិនតក់ស្លុតសោះ? ។

ព្រះពោធិសត្វបានស្ដាប់ដូច្នោះហើយ ទើបឆ្លើយប្រាប់ទៅវិញ ដោយគាថា ២ បទថា:

ទិស្វា ខុរប្បេ ធនុវេគនុណ្ណេ
ខគ្គេ គហីតេ តិក្ខិណេ តេលធោតេ
តស្មឹ ភយស្មឹ មរណេ វិយូឡ្ហេ
វេទំ អលត្ថំ វិបុលំ ឧឡារំ
សោ វេទជាតោ អជ្ឈភាវឹ អមិត្តេ
បុព្វេវ មេ ជីវិតមាសិ ចត្តំ

ន ហិ ជីវិតេ អាលយំ ករុព្ភមានោ
ករោ ករិយំ ករុព្ភ ករាចិ ។

(សេចក្តីថា) កាលយើងឃើញចោរទាំងឡាយបាញ់កូនសរដ៏ស្រួចនឹងកាន់ដាវដ៏មុត ដែលដុសខាត់ដោយប្រេង, កាលមរណភ័យនោះចូលមកដល់ចំពោះមុខហើយ យើងត្រឡប់ជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងទៅវិញ កាលបើយើងមានសេចក្តីសោមនស្សរីករាយកើតឡើងហើយ ក៏បានឈ្នះសត្រូវទាំងឡាយ ព្រោះថាជីវិតរបស់យើង ។ បានតាំងចិត្តលះបង់ទុកពីពេលមុនជាស្រេចហើយ យើងគ្មានអាឡោះអាល័យស្តាយជីវិតសោះឡើយ ; បុគ្គលអ្នកក្លាហានគប្បីធ្វើកិច្ចការរបស់បុគ្គលអ្នកក្លាហានក្នុងកាលខ្លះ ។

ព្រះបរមពោធិសត្វសំដែងសភាពរបស់ខ្លួន ជាអ្នកមានសេចក្តីក្លាហានមិនអាឡោះអាល័យស្តាយជីវិត ព្រោះបាប់សត្តាហបុត្តដូច្នោះហើយ ក៏បញ្ជូនសត្តាហបុត្តឲ្យចេញទៅ ។ ព្រះពោធិសត្វកាលវិលមកលំនៅនៃខ្លួនវិញ បានធ្វើបុណ្យទាំងឡាយមានទានជាដើម ដរាបក្ស័យជីវិតហើយទៅចាប់កំណើតថ្មីទៀតតាមយថាកម្ម ។

សត្ថា ឥមំ ធម្មទេសនំ អាហរិត្វា សម្តេចព្រះសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់នាំព្រះធម្មទេសនានេះមកសំដែងចប់ហើយ អរិយសច្ចានិ បកាសេត្វា ក៏ទ្រង់ប្រកាសអរិយសច្ចធម៌ទាំង ៤ ប្រការ លុះចប់

ចតុរារិយសច្ចទេសនាហើយ ភិក្ខុអ្នកលះបង់ចោលសេចក្ដីព្យាយាមៈនោះ ក៏បានសំរេចអរហត្តផលជាផលដ៏ខ្ពស់បំផុត សម្ដេចព្រះសុគត សំដែងធម៌នោះចប់ហើយ ទើបទ្រង់តអនុសន្ធិប្រជុំជាតកថាៈ

តទា អារក្ខិកជេដ្ឋកោ បង ឯព្រះពោធិសត្វអ្នករក្សាដងព្រៃជាមេធំគ្រានោះ លុះអន្លោលជាតិមក អហំ ឯវ បានជាអង្គតថាគតក្នុងគ្រានេះឯង ។

## គតិរបស់រឿង

ក្នុងផ្ទៃនៃរឿងនេះសសេចក្ដីឲ្យឃើញថាៈ

១ — មនុស្សដែលធ្វើជាអាណាព្យាបាលលើគេ ត្រូវតែជាអ្នកមានចិត្តក្លាហាន មានអំណត់អត់ធន់ តស៊ូនឹងឧបសគ្គទាំងពួង ត្រូវតែមានគំនិតល្អិតជ្រាលជ្រៅ ត្រូវតែមានចិត្តធ្ងន់ធ្ង មិនត្រូវមានចិត្តស្រាលត្រចៀកកក់ ឆាប់ប្រឡោតខឹងទេ មិនត្រូវគិតប្រយោជន៍ផ្ទាល់ខ្លួនហួសប្រមាណទាល់តែខូចសាមគ្គីធម៌ទេ ។

២ — អ្នកជាអាណាព្យាបាលគេ មិនត្រូវខ្ជិលច្រអូសទេ ត្រូវតែមានសេចក្ដីព្យាយាមអង់អាចលើសគេ ។

៣ — អ្នកជាអាណាព្យាបាលគេ មិនត្រូវមើលបំណាំអ្នកតូចជាងទេ ត្រូវតែជួយទំនុកបំរុងនឹងជួយការពារអ្នកតូច ក្នុងពេលដែលមានអន្តរាយមកដល់ ។

៤ — អ្នកជាអាណាព្យាបាលគេ មិនត្រូវប្រកបដោយអគតិធម៌ ៤ យ៉ាងទេ គឺ:

ក) ឆន្ទាគតិ លំអៀងព្រោះសេចក្ដីស្រឡាញ់ ។

ខ) ទោសាគតិ . . . . . . . . . . . . . . . ស្អប់ ។

គ) ភយាគតិ . . . . . . . . . . . . . . . ខ្លាច ។

ឃ) មោហាគតិ . . . . . . . . . . . . . . . ល្ងង់ ។

**ឧបជ្ឈាគាថា ចប់ ។**

ន បណ្ឌិតា ធិគុណាមាហុ ភាសាំ

បណ្ឌិតមិនដែលពោលពាក្យហួសហេតុទេ ។

---

# សេចក្ដីជូនដំណឹងរបស់ពុទ្ធសាសនបណ្ឌិត្យ

សៀវភៅទាំងឡាយដែលផ្សាយចេញអំពីក្រុមនេះ ដូចជាសៀវភៅគតិលោកឬគតិធម៌ជាដើមដែលជាវត្ថុសំខាន់ ហើយអាក់ខានពុំបានបោះពុម្ពជាយូរឆ្នាំមកហើយដោយទេសកាលវិបត្តិ ឥឡូវនេះបានបោះពុម្ពឡើងវិញរួចច្រើនមុខហើយ, លុះដល់ពាក់កណ្ដាលឆ្នាំនេះ សៀវភៅគតិលោក គតិធម៌ទាំងប៉ុន្មាន នឹងមានបរិបូណ៌ឡើងវិញ ដូចពីដើមមិនខាន ។

ហេតុនេះ, បើអស់លោក-អ្នកត្រូវការជាវសៀវភៅទាំងនោះ សូមអញ្ជើញចូលទៅជាវនៅមន្ទីរពុទ្ធសាសនបណ្ឌិត្យ ១ កន្លែង ឬ នៅបណ្ណាគារអេយស៊ុយយាន (មន្ទីរលក់សៀវភៅ នៅតំណាក់រទេះភ្លើង ភ្នំពេញ) ១ កន្លែងទៀត ។

ចំណែកអស់លោក-អ្នកនៅស្រុកក្រៅ បើត្រូវការជាវ សូមផ្ញើសំបុត្រទៅពុទ្ធសាសនបណ្ឌិត្យ ៗ នឹងចាត់ចែងផ្ញើរជូនភ្លាមដល់ទីលំនៅរបស់លោក-អ្នក ជាពុំខាន ។